SPE/MSC-86

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

# ការគាំទ្រហិរញ្ញវត្ថុ និង បច្ចេកទេស
# ដល់
# គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់
# ២០០១-២០០៥

**តាមរយៈ**

**កម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា**

**និង**

**គំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋានរបស់អង្គការសហប្រជាជាតិ**

**គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា**

**ខែធ្នូ ឆ្នាំ២០០៤**

library.ncdd.gov.kh
008063

បណ្ណាល័យ
គ.ជ.អ.ម

# ការគាំទ្រហិរញ្ញវត្ថុ និង បច្ចេកទេស
# តាមរយៈ កម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា និង
# គំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន ដល់គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់
# ២០០១-២០០៥

របាយការណ៍នេះសង្ខេបពីការគាំទ្រទូទៅ ដែលកម្មវិធីសិលានិងគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន (PLG) បានផ្តល់ដល់គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ (NCSC) អនុគណៈកម្មាធិការនានា និងក្រសួងដែលជាសមាជិក NCSC ព្រមទាំងមន្ទីរវិស័យជុំវិញខេត្ត-ក្រុង ចាប់តាំងពី NCSC ត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០០៤ ព្រមទាំងថវិកាវិភាជឆ្នាំ២០០៥ ខាងមុខនេះផងដែរ។ របាយការណ៍នេះនឹងផ្តោតទៅលើការគាំទ្រជាទូទៅ ដូចជា ការគាំទ្រដល់ក្រសួងនីមួយៗ ដែលជាសមាជិក NCSC និងលទ្ធផលសំខាន់ៗដែលសំរេចបាន តាមរយៈនៃការគាំទ្ររបស់កម្មវិធីសិលា និងគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាននេះ។ របាយការណ៍បានគូសបញ្ជាក់ថា ក្នុងចំណោមធនធានហិរញ្ញវត្ថុប្រមាណ ១៣០ លានដុល្លារអាមេរិក ដែលបានកៀងគរនិងគាំទ្រកម្មវិធី ក្នុងក្របខ័ណ្ឌកម្មវិធីសិលា ចន្លោះពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៥ ថវិកាចំនួន ៤៤.៦ លានដុល្លារអាមេរិក ឬ ស្មើនឹង ៣៣%នៃថវិកាសរុបត្រូវបានវិភាជសំរាប់គាំទ្រដល់ការចងក្រង ការពង្រឹងសមត្ថភាព និង ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈវិមជ្ឈការ ក្រោមអាណត្តិរបស់ NCSC ។ ក្នុងថវិកាចំនួន ៤៤.៦ លានដុល្លារអាមេរិកនេះ ថវិកាចំនួន ៣៧ លានដុល្លារអាមេរិក ឬ ស្មើនឹង៨៤% ត្រូវបានវិភាជប្រចាំឆ្នាំ សំរាប់គាំទ្រដោយផ្ទាល់ ដល់ក្រសួងដែលជាសមាជិក NCSC ខេត្ត-ក្រុង និងឃុំ-សង្កាត់ ដែលជាអ្នកទទួលខុសត្រូវលើការរៀបចំផែនការថវិកា និងលើ ការអនុវត្តន៍រាល់សកម្មភាព ស្របទៅតាមអាណត្តិរបស់ស្ថាប័ននីមួយៗ ។ សមតុល្យចំនួន ៧ លានដុល្លារអាមេរិក ឬ ស្មើនឹង ១៦%ទៀត ត្រូវបានវិភាជសំរាប់ផ្តល់សេវាប្រឹក្សាដល់ក្រសួង និងខេត្ត-ក្រុង ដើម្បីគាំទ្រ ការរៀបចំការបណ្តុះបណ្តាល និងការអនុវត្តន៍លិខិតបទដ្ឋាន យុទ្ធសាស្ត្រ ប្រព័ន្ធ ការតាមដាន និងការត្រួតពិនិត្យសកម្មភាព ដែលទាក់ទងដោយផ្ទាល់ជាមួយនឹងអាណត្តិរបស់ NCSC ។ របាយការណ៍នេះមិនបាន គ្របដណ្តប់ទៅលើធនធានវិនិយោគផ្សេងៗទៀត ដែលត្រូវបានផ្តល់ដល់ខេត្ត-ក្រុង ក្នុងរយៈពេល៥ឆ្នាំនេះទេ ហើយក៏មិនបានគ្របដណ្តប់លើការគាំទ្រ ដែលបានផ្តល់ដល់ក្រសួងនានា ដែលមិនមែនជាសមាជិក NCSC នោះដែរ។

352.38
FIN
sh: Report

**សទេគា**

ចាប់តាំងពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០០ កម្មវិធីសិលា ជាកម្មវិធីមួយរបស់រាជរដ្ឋាភិបាល ដែលគាំទ្រដោយគំរោងរបស់អង្គការសហប្រជាជាតិ (ស្តារនិងស្ថាបនាកម្ពុជាឡើងវិញ-CARERE) ត្រូវបានរៀបចំ អនុវត្តសាកល្បង និងបានធ្វើការកែសំរួល និងបន្តពង្រឹងជាប្រចាំ នូវប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្តន៏តាមបែបវិមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់ ព្រមទាំងប្រព័ន្ធ និងរចនាសម្ព័ន្ធគាំទ្រ និងត្រួតពិនិត្យការចាត់ចែងនៅថ្នាក់ខេត្ត-ក្រុង ។ នៅត្រឹមដំណាច់ឆ្នាំ២០០០ ប្រព័ន្ធកសាងផែនការ និងការអនុវត្តន៏ ត្រូវបានអនុវត្តចំនួន៤វគ្គ ហើយវិសាលភាពរបស់កម្មវិធី បានគ្របដណ្តប់លើឃុំចំនួន៣៥០ ក្នុងខេត្តចំនួន៩ ។ យើងបានទទួលនូវបទពិសោធន៏ជាច្រើនពីដំណាក់កាលសាកល្បងនេះ ជាពិសេស បទពិសោធន៏ក្នុងភាពជាដៃគូជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងអភិវឌ្ឍន៏ជនបទ និងអភិបាលខេត្ត-ក្រុង ។ បទពិសោធន៏ទាំងនេះ គឺជាឧបករណ៏មួយ ដែលជាមូលដ្ឋានសំរាប់បញ្ជាំងអោយរាជរដ្ឋាភិបាល សំរេចទទួលយកគោលនយោបាយវិមជ្ឈការ គឺជាគោលនយោបាយជាតិ ហើយផ្អែកលើគោលនយោបាយនេះ ក្របខ័ណ្ឌច្បាប់មួយត្រូវបានបង្កើតឡើង ។ ដំណាក់កាលទី២ នៃកម្មវិធីសិលាដែលមានរយៈពេល៥ឆ្នាំ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០ និងអនុម័តដោយគណៈរដ្ឋមន្ត្រី នៅក្នុងខែមករា ឆ្នាំ២០០១ ជាក្របខ័ណ្ឌសំរាប់កៀងគរនិងសំរបសំរួលជំនួយ ដើម្បីគាំទ្រកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ។ ក្នុងពេលជាមួយគ្នានោះដែរ គំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន ដែលគាំទ្រដោយអង្គការសហប្រជាជាតិ ត្រូវបានអនុម័តយក សំរាប់ផ្តល់ការគាំទ្រចំបងដល់ការអនុវត្តន៏កំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការនេះ តាមរយៈក្របខ័ណ្ឌកម្មវិធីសិលា ចាប់តាំងពីខែកក្កដា ឆ្នាំ ២០០១ ដល់ខែធ្នូ ឆ្នាំ២០០៥ ។

រាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ នៅខែមីនា ឆ្នាំ២០០១ ។ នៅក្នុងខែមិថុនា ឆ្នាំ២០០១ គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ ត្រូវបានបង្កើតឡើងជាផ្លូវការ ជាស្ថាប័នជាតិទទួលខុសត្រូវលើការបង្កើតក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈវិមជ្ឈការ សំរាប់គ្រប់គ្រងការអនុវត្តន៏ច្បាប់ក្រោយពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងខែកុម្ភៈ ឆ្នាំ២០០២ និងដើម្បីទទួលខុសត្រូវលើការត្រួតពិនិត្យតាមដាន និងការកែសំរួលជាបន្តនូវរាល់គោលនយោបាយ និងលិខិតបទដ្ឋានផ្សេងៗ ក្នុងរយៈពេល៥ឆ្នាំនៃអាណតិទី១ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ជាប់ឆ្នោតទាំង១.៦២១ ។ ក្នុងពេលជាមួយគ្នានេះដែរ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន(DoLA)នៃក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើង ដើម្បីសំរបសំរួលការអនុវត្តន៏ក្របខ័ណ្ឌច្បាប់ ដែលបានអនុម័តដោយ NCSC និងដើម្បីផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ចាប់តាំងពី NCSC បានបង្កើតមក ធនធានហិរញ្ញវត្ថុ និង បច្ចេកទេសជាច្រើនត្រូវបានកៀងគរវិភាជ និងផ្ទេរជាលក្ខណៈប្រព័ន្ធជារៀងរាល់ឆ្នាំ ក្រោមក្របខ័ណ្ឌកម្មវិធីសិលា ដល់ក្រសួងនានាដែលជាសមាជិក NCSC ដើម្បីគាំទ្រការរៀបចំក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធគ្រប់គ្រងនានា ដូចជា ការរៀបចំ និងការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលរបស់ NCSC សំរាប់មន្ត្រីថ្នាក់ជាតិ ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ព្រមទាំងកម្មវិធីគាំទ្រទូលំទូលាយនៅថ្នាក់ជាតិ និង ខេត្ត-ក្រុង សំរាប់ការអនុវត្តន៍ និងការតាមដានបន្ត និងការពង្រឹងគោលនយោបាយវិមជ្ឈការ ។

តាមរយៈសិក្ខាសាលាជាតិប្រចាំឆ្នាំ ដែលបានរៀបចំរួមគ្នាដោយ NCSC និងកម្មវិធីសិលា តាំងពីឆ្នាំ ២០០១មក ការណែនាំគោលនយោបាយសំខាន់ៗ ត្រូវបានផ្តល់ដល់ក្រសួងដែលជាសមាជិក និងខេត្ត-ក្រុងទាំងអស់ ដើម្បីរៀបចំបង្កើតផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលផ្តោតទៅលើការពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍន៍មូលដ្ឋាននៅទូទាំងប្រទេស ។ នៅក្នុងសិក្ខាសាលាជាតិឆ្នាំ២០០២ ប្រធាន NCSC បានស្នើអោយកម្មវិធីសិលាពង្រីកការគាំទ្ររបស់ខ្លួនអោយឆាប់រហ័ស ដល់ខេត្ត-ក្រុង៧ផ្សេងទៀត និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលនៅសេសសល់ ។ កិច្ចខិតខំប្រឹងប្រែងក្នុងការកៀងគរធនធានប្រកបដោយជោគជ័យត្រូវបានធ្វើ ឡើងដោយកម្មវិធីសិលា ជាមួយនឹងដៃគូម្ចាស់ជំនួយ ហើយតាំងពីខែមីនា ឆ្នាំ២០០៣ ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស ត្រូវបានពង្រីកដល់គ្រប់ខេត្ត-ក្រុងទាំង២៤ និង ១.៦២១ ឃុំ-សង្កាត់ ។

## ១. ការគាំទ្រសរុបដែលបានផ្តល់ដោយកម្មវិធីសិលា/PLG ដល់ NCSC

### ១.១ ការគាំទ្រសរុបផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស ដែលបានផ្តល់ដល់ NCSC

ដូចមានបង្ហាញនៅក្នុងតារាង១ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ (២០០១-២០០៥) ថវិកាសរុបចំនួន ៤៤.៦ លានដុល្លារអាមេរិក សំរាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស ត្រូវបានកម្មវិធីសិលា/PLG ផ្តល់ទៅស្ថានប័នដូចខាងក្រោម :

**ក) NCSC អនុគណៈកម្មាធិការរបស់ NCSC និងក្រសួងដែលជាសមាជិក NCSC :** សំរាប់ការបង្កើតក្របខ័ណ្ឌច្បាប់ ការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រង ការរៀបចំនិងការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលទូទាំងប្រទេស ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ដោយថ្នាក់ជាតិ ព្រមទាំងសំភារៈ។

**ខ) រដ្ឋបាលខេត្ត-ក្រុង ក្រោមការដឹកនាំរបស់អភិបាលខេត្ត-ក្រុង :** សំរាប់គាំទ្រជាទូទៅដល់ការអនុវត្តន៍អាណត្តិរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ សំរាប់ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលរបស់NCSCដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយសំរាប់ហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាល សំភារៈ និងការចំណាយគាំទ្រការអនុវត្តន៍គំរោង ។

**គ) ក្រុមប្រឹក្សាឃុំ-សង្កាត់ :** ការគាំទ្រនេះត្រូវបានផ្តល់តាមរយៈមូលនិធិឃុំ-សង្កាត់ សំរាប់ផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍របស់ឃុំ-សង្កាត់ និងតាមរយៈការវិនិយោគបន្ថែមផ្សេងៗទៀត ដែលត្រូវបានវិភាជទៅអោយឃុំ-សង្កាត់គោលដៅមួយចំនួន ដោយផ្ទាល់តែម្តង។

**តារាង១ : ការគាំទ្រសរុបដែលបានផ្តល់ដោយកម្មវិធីសិលា/PLG ដល់ NCSC**

| ប្រភេទ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | សរុប |
|---|---|---|---|---|---|---|
| **១. ក្រសួងសមាជិក NCSC** | | | | | | |
| **១.១ ក្រសួងមហាផ្ទៃ** | **៥៧០.៦៥៧** | **១.៨១១.៦១១** | **១.៧៣២.៧២៧** | **២.៣៨៦.៧៤៩** | **២.៤០៩.០០០** | **៨.៩១០.៧៤៤** |
| ថវិកាគាំទ្រ | ២៥៥.៦៥៧ | ១.០៤០.៦១១ | ១.២៨១.៧២៧ | ១.៤៣៨.៧៤៩ | ១.៤៥០.០០០ | ៥.៤៦៦.៧៤៤ |
| សហប្រតិបត្តិការបច្ចេកទេស | ៣១៥.០០០ | ៧៧១.០០០ | ៤៥១.០០០ | ៩៤៨.០០០ | ៩៥៩.០០០ | ៣.៤៤៤.០០០ |
| **១.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **២០១.៩៧២** | **៣៨៥.៣៩០** | **៦០១.៩៥២** | **៦៨៨.៥៥៤** | **៦៨៤.៣៥០** | **២.៥៦២.២១៨** |
| ថវិកាគាំទ្រ | ៦៤.៩៧២ | ១៩៥.០៤០ | ៣៨៤.៦០២ | ៤៤៤.២០៤ | ៤៤០.០០០ | ១.៥២៨.៨១៨ |
| សហប្រតិបត្តិការបច្ចេកទេស | ១៣៧.០០០ | ១៩០.៣៥០ | ២១៧.៣៥០ | ២៤៤.៣៥០ | ២៤៤.៣៥០ | ១.០៣៣.៤០០ |
| **១.៣ ក្រសួងផែនការ** | **១៨០.៦៤៤** | **៣៣៧.៤០០** | **៤១៩.៦៤៥** | **៤៤៨.៩៨៣** | **៤៥០.៤៦០** | **១.៨៣៧.១៣២** |
| ថវិកាគាំទ្រ | ៦៦.៨៤៤ | ១៤៤.០០០ | ១៩៨.៦៨៥ | ២៣៤.០២៣ | ២៣៥.៥០០ | ៨៧៩.០៥២ |
| សហប្រតិបត្តិការបច្ចេកទេស | ១១៣.៨០០ | ១៩៣.៤០០ | ២២០.៩៦០ | ២១៤.៩៦០ | ២១៤.៩៦០ | ៩៥៨.០៨០ |
| **១.៤ ក្រសួងអភិវឌ្ឍន៍ជនបទ** | **១៨៧.៧១៩** | **៥២១.៥០៤** | **៧០៦.៥៣៧** | **៧២៩.៣៧៧** | **៦៨៨.៨៦០** | **២.៨៣៣.៩៩៧** |
| ថវិកាគាំទ្រ | ៩២.៧១៩ | ៣២០.២០៤ | ៤៥២.៦៧៧ | ៤៩៥.៥១៧ | ៤៩៥.០០០ | ១.៨៥៦.១១៧ |
| សហប្រតិបត្តិការបច្ចេកទេស | ៩៥.០០០ | ២០១.៣០០ | ២៥៣.៨៦០ | ២៣៣.៨៦០ | ១៩៣.៨៦០ | ៩៧៧.៨៨០ |
| **១.៥ ក្រសួងកិច្ចការនារី** | **១២៩.៦៨៦** | **២៣៧.៤៥៩** | **៣៩១.០៥៦** | **៣៦១.៤១៦** | **៣៧៣.៤១៦** | **១.៤៥៣.១០៩** |
| ថវិកាគាំទ្រ | ៦៤.៤៤៦ | ១៤៩.៦៥៩ | ២០០.៦៥៦ | ២៦១.០១៦ | ២៧៣.០១៦ | ៩៤៨.៨៦៩ |
| សហប្រតិបត្តិការបច្ចេកទេស | ៦៥.២៤០ | ៨៧.៨០០ | ១៩០.៤០០ | ១០០.៤០០ | ១០០.៤០០ | ៥០៤.២៤០ |
| **១.៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | ០ | ០ | **១៥៥.៧៥៩** | **៦៣៧.៦១៦** | **៥១៦.៨៧៦** | **១.៣១០.២៥១** |
| ថវិកាគាំទ្រ | | | ១០៣.៧៥៩ | ៥៣៣.៦១៦ | ៤០០.៣៧៦ | ១.០៣៧.៧៥១ |
| សហប្រតិបត្តិការបច្ចេកទេស | | | ៥២.០០០ | ១០៤.០០០ | ១១៦.៥០០ | ២៧២.៥០០ |
| **២. សង្ខេប** | | | | | | |
| **២.១ ថវិកាគាំទ្រ** | **៥៤៤.៦៣៧** | **១.៨៤៩.៥៥០** | **២.៦២២.១៤៥** | **៣.៤០៧.១២៥** | **៣.២៩៣.៨៩២** | **១១.៧១៧.៣៤៨** |
| **២.២ សហប្រតិបត្តិការបច្ចេកទេស** | **៧២៦.០៤០** | **១.៤៤៣.៨៥០** | **១.៣៤៥.៩៧០** | **១.៨៤៥.៩៧០** | **១.៨២៩.០៧០** | **៧.១៩០.១០០** |
| **២.៣ ការចូលរួមរបស់មូលនិធិឃុំ-សង្កាត់** | | **១.៤០០.០០០** | **៥.៨០០.០០០** | **៦.៧០០.០០០** | **៦.៧០០.០០០** | **២០.៦០០.០០០** |
| **២.៤ ការវិភាជមូលនិធិសំរាប់ឃុំ-សង្កាត់គោលដៅ** | | | | **២.១៦៤.០០០** | ០ | **២.១៦៤.០០០** |
| **២.៥ អគារ/សំភារៈ** | | | | | | **២.៤១៦.៥០០** |
| **៣. សរុបរួម** | **១.២៧០.៦៧៧** | **៤.៦៩៣.៤០០** | **៩.៧៦៧.៧១៥** | **១៤.១១៦.៦៥៩** | **១១.៨២២.៩៦២** | **៤៤.០៨៧.៩៤៨** |

## ១.២ គោលនយោបាយ លិខិតបទដ្ឋាន និងឯកសារគតិយុត្ត

តារាងសង្ខេប៤ទំព័រ ដែលភ្ជាប់ជាឧបសម្ព័ន្ធទី២នៃរបាយការណ៍នេះ លើកឡើងពីអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ គោលការណ៍ណែនាំ និងសេចក្តីសំរេចនានា ដែលបានអនុម័តដោយ NCSC និងដែលបានគាំទ្រហិរញ្ញវត្ថុដោយកម្មវិធីសិលា/PLG ។ តារាងខាងក្រោម សង្ខេបពីពតិមាននៅក្នុងឧបសម្ព័ន្ធនោះ ដែលត្រូវបំបែកទៅតាម អនុគណៈកម្មាធិការនីមួយៗរបស់ NCSC ។

**តារាង២ : ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ NCSC លើផ្នែកឧបករណ៍ច្បាប់ សេចក្តីណែនាំ គោលការណ៍ណែនាំ និងសេចក្តីសំរេច**

| អនុគណៈកម្មាធិការ | អនុក្រឹត្យ | ប្រកាស | សេចក្តីណែនាំ | គោលការណ៍ណែនាំ | សេចក្តីសំរេច | សរុប |
|---|---|---|---|---|---|---|
| រចនាសម្ព័ន្ធនិងតួនាទី | ១ | ៥ | | ៧ | ៥ | ១៨ |
| ផែនការនិងអភិវឌ្ឍន៍ | | ៤ | ២ | ៤ | ២ | ១២ |
| កិច្ចការហិរញ្ញវត្ថុ | ៤ | ១៦ | | ៥ | ១ | ២៦ |
| ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព | | ១ | ១៧ | ១ | ៣ | ២២ |
| **សរុបរួម** | **៥** | **២៦** | **១៩** | **១៧** | **១១** | **៧៨** |

# ២. ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងមហាផ្ទៃនិងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

## ២.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុសរុប : ឆ្នាំ ២០០១-២០០៥

ជារៀងរាល់ឆ្នាំ ធនធានទាំងឡាយដែលគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋានបានកៀងគរ ត្រូវបានវិភាជទៅនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ (DoLA) ព្រមទាំងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង (LAU) ដើម្បីគាំទ្រគោលនយោបាយ ការអនុវត្តន៍ ការតាមដាននិងត្រួតពិនិត្យ ការបណ្តុះបណ្តាល និងចំណាយប្រតិបត្តិការ ។ ដូចបានរំលេចនៅក្នុងតារាង៣ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ ថវិកាសរុបចំនួន ៥៣០.០០០ ដុល្លារអាមេរិក ត្រូវបានវិភាជទៅអោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ហើយថវិកាសរុបប្រមាណ ៥ លានដុល្លារអាមេរិក ត្រូវបានវិភាជ សំរាប់គាំទ្រអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង។

| តារាង៣ : ការគាំទ្រថវិការបស់កម្មវិធីសិលា/PLG ដល់ក្រសួងមហាផ្ទៃ | | | | | | |
|---|---|---|---|---|---|---|
| **ប្រភេទ** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | ៥០៩ | ១.២៨៣ | ១.៦២១ | ១.៦២១ | ១.៦២១ | ១.៦២១ |
| ចំនួនខេត្ត-ក្រុង | ១២ | ១៧ | ២៤ | ២៤ | ២៤ | ២៤ |
| **ថវិកាវិភាជន៍** | | | | | | |
| ក្រសួងមហាផ្ទៃ/DoLA | ៣០.០០០ | ២០០.០០០ | ១០០.០០០ | ១០០.០០០ | ១០០.០០០ | ៥៣០.០០០ |
| អង្គភាពរដ្ឋបាលមូលដ្ឋាន(LAU) | ២២៥.៦៥៧ | ៨៤០.៦១១ | ១.១៨១.៧២៧ | ១.៣៣៨.៧៤៩ | ១.៣៥០.០០០ | ៤.៩៣៦.៧៤៤ |
| **ថវិកាសរុប** | **២៥៥.៦៥៧** | **១.០៤០.៦១១** | **១.២៨១.៧២៧** | **១.៤៣៨.៧៤៩** | **១.៤៥០.០០០** | **៥.៤៦៦.៧៤៤** |

## ២.២ សហប្រតិបត្តិការបច្ចេកទេសសរុប : ឆ្នាំ២០០១-២០០៥

ចាប់តាំងពីការបង្កើតនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ទីប្រឹក្សាកម្មវិធីសិលា/PLG និងអ្នកពិគ្រោះយោបល់ ដែលត្រូវបានបញ្ជូនទៅនាយកដ្ឋាននេះ បានគាំទ្រដល់ការបង្កើតក្របខ័ណ្ឌច្បាប់និងនីតិវិធីតាមបែបវិមជ្ឈការ ដល់ការរៀបចំនិងការអនុវត្តន៍យុទ្ធសាស្ត្របណ្តុះបណ្តាល និងកម្មវិធីសិក្សាថ្នាក់ជាតិ ដល់ការរៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រង និងរបាយការណ៍ ព្រមទាំងដល់ការពង្រឹងស្ថាប័ននៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) ។ ដូចបានរំលេចនៅក្នុងតារាង៤ខាងក្រោម ចាប់តាំងពីឆ្នាំ២០០៣មក DoLA បានទទួលការ គាំទ្រជាមធ្យម ពីទីប្រឹក្សាអន្តរជាតិម្នាក់ និងពីទីប្រឹក្សាជាតិចំនួន៤-៥នាក់ ។

| តារាង៤ : សហប្រតិបត្តិការបច្ចេកទេសរបស់កម្មវិធីសិលា/PLG ជាមួយក្រសួងមហាផ្ទៃ | | | | | | |
|---|---|---|---|---|---|---|
| **ប្រភេទ** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | ៥០៩ | ១.២៨៣ | ១.៦២១ | ១.៦២១ | ១.៦២១ | ១.៦២១ |
| ចំនួនខេត្ត-ក្រុង | ១២ | ១៧ | ២៤ | ២៤ | ២៤ | ២៤ |
| **ក្រសួងមហាផ្ទៃ/DoLA** | | | | | | |
| ទីប្រឹក្សា/អ្នកពិគ្រោះយោបល់អន្តរជាតិ | ១ | ១ | ១ | ១ | ១ | |
| ទីប្រឹក្សាជាតិ | ៤ | ៤ | ៤ | ៣ | ៤ | |
| **ទីប្រឹក្សាសរុប** | **៥** | **៥** | **៥** | **៤** | **៥** | |
| **ចំណាយសរុប** | **៩០.០០០** | **១៦៩.០០០** | **១៦៩.០០០** | **១៥៨.០០០** | **១៦៩.០០០** | **៧៥៥.០០០** |
| **ខេត្ត-ក្រុង** | | | | | | |
| ទីប្រឹក្សាសំរាប់អភិបាលខេត្ត-ក្រុង | ១០ | ១៥ | ២២ | ២២ | ២២ | |
| ទីប្រឹក្សាអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត | ៣០ | ៣៥ | ៤០ | ៤០ | ៤០ | |
| **ទីប្រឹក្សាសរុប** | **៤០** | **៥០** | **៦២** | **៦២** | **៦២** | |
| **ចំណាយសរុប** | **២២៥.០០០** | **៦០២.០០០** | **៧៩០.០០០** | **៧៩០.០០០** | **៧៩០.០០០** | **៣.១៩៧.០០០** |
| ទីប្រឹក្សាសរុបរួម | **៤៥** | **៥៥** | **៦៧** | **៦៦** | **៦៧** | |
| ចំណាយសរុបរួម | **៣១៥.០០០** | **៧៧១.០០០** | **៩៥៩.០០០** | **៩៤៨.០០០** | **៩៥៩.០០០** | **៣.៩៥២.០០០** |

នៅថ្នាក់ខេត្ត-ក្រុង មានទីប្រឹក្សាជាតិចំនួន២២នាក់ ដែលបានជួយផ្ដល់ប្រឹក្សាដល់អភិបាលខេត្ត-ក្រុង និងទីប្រឹក្សាជាតិចំនួន ៤០នាក់ផ្សេងទៀត ដែលបានជួយផ្ដល់ប្រឹក្សាដល់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត - ក្រុង ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រង ការតាមដានត្រួតពិនិត្យនិងការវាយតំលៃ ការសំរបសំរួល ការបង្កើតភាពជាដៃគូ ការផ្ដល់ព័ត៌មានដល់មូលដ្ឋាន និងគណនេយ្យភាព ។ ដូចបានរំលេច នៅក្នុងតារាង៤ខាងលើ ក្នុងរយៈពេល៥ឆ្នាំ សហប្រតិបត្តិការបច្ចេកទេស មានតម្លៃជាទឹកប្រាក់សរុបប្រមាណជា ៣.៩ លានដុល្លារអាមេរិក ត្រូវបានផ្ដល់ឱ្យ សម្រាប់គាំទ្រមុខងាររបស់អភិបាលខេត្ត-ក្រុង និង អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង ។

## ២.៣ សមិទ្ធផលសំខាន់ៗ

### ២.៣.១ ការបណ្ដុះបណ្ដាល

ចាប់តាំងពីឆ្នាំ២០០១មក ទីប្រឹក្សាគំរោង PLG ដែលត្រូវបានបញ្ជូនទៅ DoLA បានជួយក្នុងការរៀបចំផែនការបណ្ដុះបណ្ដាលប្រចាំឆ្នាំទាំងអស់របស់ NCSC ដោយផ្ដោតទៅលើ ទាំងមន្ត្រី LAU ដែលត្រូវបានបញ្ជូនទៅគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មៀនឃុំ-សង្កាត់ និងគណៈកម្មាធិការកសាងផែនការនិងថវិកា ។ ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស ដែលបានផ្ដល់អោយរួមមានការងារមួយចំនួន : ការចងក្រងយុទ្ធសាស្ត្របណ្ដុះបណ្ដាល កម្មវិធីសិក្សា ឯកសារណែនាំ និងសំភារៈបណ្ដុះបណ្ដាល ការរៀបចំនិងការអនុវត្តន៍វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ព្រមទាំងការបណ្ដុះបណ្ដាលនៅថ្នាក់ឃុំ-សង្កាត់ ។ តារាង៥ខាងក្រោម សង្ខេបនូវរាល់វគ្គបណ្ដុះបណ្ដាលសំខាន់ៗ ដែលត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០១មក ហើយដែលត្រូវបានគាំទ្រដោយកម្មវិធីសិលា/PLG ក្នុងភាពជាដៃគូជាមួយ ADB GTZ និង UNDP/DSP ។

| តារាង៥ : ការគាំទ្រកម្មវិធីបណ្តុះបណ្តាលរបស់ NCSC | | | | | |
|---|---|---|---|---|---|
| ល.រ | វគ្គបណ្តុះបណ្តាល | កាលបរិច្ឆេទ | ចំនួនអ្នកដែលបានបណ្តុះបណ្តាល | | |
| | | | ខេត្ត/ស្រុក | ឃុំ-សង្កាត់ | សរុប |
| **២០០២** | | | | | |
| ១ | វគ្គតំរង់ទិសវិមជ្ឈការ | មីនា-មិថុនា | ៥៥៣ | ១១.៧៣៦ | **១២.២៨៩** |
| ២ | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់ | ឧសភា-មិថុនា | ៧១៧ | ៩.៧៥១ | **១០.៤៦៨** |
| ៣ | ដំណើរការកសាងផែនការឃុំ-សង្កាត់ | មិថុនា-សីហា | ៨៨២ | ១៦.០០៩ | **១៦.៨៩១** |
| ៤ | ការរៀបចំគំរោងឃុំ-សង្កាត់ | វិច្ឆិកា-ធ្នូ | ៧២៣ | ៨.៣៨៦ | **៩.១០៩** |
| **២០០៣** | | | | | |
| ៥ | ការគ្រប់គ្រងលទ្ធកម្ម និងកិច្ចសន្យាឃុំ-សង្កាត់ | កុម្ភៈ | ១.២១០ | ១១.០៤៨ | **១២.២៥៨** |
| ៦ | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់ (២) | មីនា | ៥៣៩ | ៥.៤៨២ | **៦.០២១** |
| ៧ | ប្រព័ន្ធរបាយការណ៍ឃុំ-សង្កាត់ | មីនា-វិច្ឆិកា | ៥២១ | ៤.៩៤៥ | **៥.៤៦៦** |
| ៨ | ការរៀបចំកម្មវិធីវិនិយោគឃុំ-សង្កាត់ | សីហា | ១.០៩៧ | ១៧.៥១០ | **១៨.៦០៧** |
| ៩ | គោលនយោបាយជនជាតិភាគតិចនៅតំបន់ខ្ពង់រាប | កញ្ញា | ៤០ | | **៤០** |
| ១០ | បរិស្ថាន និង ការកាន់កាប់ដីធ្លីឃុំ-សង្កាត់ | វិច្ឆិកា-ធ្នូ | ៩២២ | | **៩២២** |
| **២០០៤** | | | | | |
| ១១ | ការអនុវត្តន៍គំរោងដែលគាំទ្រដោយមូលនិធិឃុំ-សង្កាត់ | កុម្ភៈ | ១.១០២ | ១.២៨២ | **១២.៣៨៤** |
| ១២ | ជំនាញសំរបសំរួល | មេសា | ៩៨៦ | | **៩៨៦** |
| ១៣ | ការតាមដាន និង វាយតំលៃគំរោងអភិវឌ្ឍន៍មូលដ្ឋាន | ឧសភា | ៩០០ | ៥.១៧៤ | **៦.០៧៤** |
| ១៤ | គោលនយោបាយជនជាតិភាគតិចនៅតំបន់ខ្ពង់រាប | មិថុនា | ៤៣ | | **៤៣** |
| ១៥ | អគ្រានុកូលដ្ឋាន | សីហា | ១.២១៩ | ១១.០៨៩ | **១២.៣០៨** |

## ២.៣.២ លិខិតបទដ្ឋាន ប្រព័ន្ធ និងសេចក្តីណែនាំ

ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ ភាគច្រើននៃលិខិតបទដ្ឋាន គោលការណ៍ណែនាំ និងសេចក្តីណែនាំ ដែលពាក់ព័ន្ធនឹងដំណើរការគ្រប់គ្រង និងដំណើរការអនុវត្តន៍វិមជ្ឈការ ត្រូវបានដាក់ចេញដោយក្រសួងមហាផ្ទៃ ដោយមានការគាំទ្រផ្នែកបច្ចេកទេស ពីទីប្រឹក្សាគំរោង PLG ។ ការគាំទ្រសំរាប់ការប្រជុំ

ថ្នាក់គ្រប់គ្រង សិក្ខាសាលា ការអនុវត្តន៍សាកល្បងគំនិតផ្តួចផ្តើម ការពិនិត្យគំរោងឡើងវិញនៅថ្នាក់ខេត្ត-ក្រុង និងការគាំទ្រលើការរៀបចំសមាជក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្នាក់ខេត្ត-ក្រុង បានផ្តល់លទ្ធភាពអោយមានដំណើរការផ្តល់យោបល់ត្រលប់ និងការពិគ្រោះយោបល់ឥតឈប់ឈរ រវាងថ្នាក់ជាតិ ខេត្ត-ក្រុង និងឃុំ-សង្កាត់ ដែលពាក់ព័ន្ធទៅនឹងការរៀបចំ ការកសាងផែនការសកម្មភាព ការកែសំរួលសេចក្តីណែនាំ ហើយនៅឆ្នាំ២០០៤នេះ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង ក៏ត្រូវបានបង្កើតឡើងជាផ្លូវការ នៅក្នុងសាលាខេត្ត-ក្រុងផងដែរ ។

### ២.៣.៣ ប្រព័ន្ធគ្រប់គ្រងព័ត៌មាន

ប្រព័ន្ធព័ត៌មានគំរោងកិច្ចសន្យាមួយត្រូវបានរៀបចំឡើងដោយគំរោង PLG និងថែរក្សាដោយខេត្ត-ក្រុងទាំង២៤ ។ ប្រព័ន្ធព័ត៌មាននេះ បានផ្តល់លទ្ធភាពអោយយើងអាចធ្វើការតាមដានទូវរាល់ការអនុវត្តន៍គំរោងរបស់ឃុំ-សង្កាត់ទាំងអស់ ហើយប្រព័ន្ធនេះត្រូវបានផ្ទេរ ទៅក្រោមការគ្រប់គ្រងរបស់ DoLA នៃក្រសួងមហាផ្ទៃ ក្នុងឆ្នាំ ២០០៤ ។ ជាងនេះទៅទៀត បណ្តាញទំនាក់ទំនងអេឡិចត្រូនិចត្រូវបានបង្កើតឡើងនៅក្នុង DoLA សំរាប់ធ្វើការទំនាក់ទំនងផ្ទៃក្នុង និងជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង ។

### ២.៣.៤ ហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាល/សំភារៈ

តាមរយៈការគាំទ្រថវិកាពីកម្មវិធីសិលា ការិយាល័យ LAU នៅក្នុងគណៈកម្មាធិការប្រតិបត្តិខេត្តនៅក្នុងខេត្តចំនួន១១ ត្រូវបានជួសជុល ការិយាល័យគណៈកម្មាធិការប្រតិបត្តិខេត្ត ត្រូវបានសាងសង់ថ្មី នៅក្នុងទីធ្លាសាលាខេត្តចំនួន៨ ហើយLAUក្នុងខេត្ត-ក្រុងទាំង២៤ ទទួលបានម៉ូតូ កំព្យូទ័រ និងសំភារៈការិយាល័យ សំរាប់បំពេញភារៈកិច្ចរបស់ខ្លួន ។

## ៣. ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិ

### ៣.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុសរុប : ឆ្នាំ ២០០១-២០០៥

ជារៀងរាល់ឆ្នាំ ធនធានរបស់កម្មវិធីសិលា/PLG ត្រូវបានវិភាជដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន រតនាគារជាតិ និងអង្គភាពហិរញ្ញវត្ថុខេត្ត-ក្រុង ដើម្បីគាំទ្រដល់វិមជ្ឈការសារពើពន្ធ ការគ្រប់គ្រងហិរញ្ញវត្ថុ គណនី និងរបាយការណ៍ហិរញ្ញវត្ថុ ពាក់ព័ន្ធទៅនឹងមូលនិធិឃុំ-សង្កាត់ មូលនិធិវិនិយោគខេត្ត-ក្រុង និងការចំណាយគាំទ្រកម្មវិធីថ្នាក់ខេត្ត-ក្រុង ។ ដូចបានរំលេចនៅក្នុងតារាង៦ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ ថវិកាសរុបចំនួន ២៣០.០០០ ដុល្លារអាមេរិក ត្រូវបានវិភាជដល់ក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ និងរតនាគារជាតិ ហើយថវិកាចំនួន ១,៣ លានដុល្លារអាមេរិក ត្រូវបានវិភាជដល់អង្គភាពហិរញ្ញវត្ថុថ្នាក់ខេត្ត-ក្រុងខាងលើ ដើម្បីគាំទ្រគោលបំណងនេះ។

| តារាង៦ : ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ | | | | | | |
|---|---|---|---|---|---|---|
| ប្រភេទ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | សរុប |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | ៥០៩ | ១.២៨៣ | ១.៦២១ | ១.៦២១ | ១.៦២១ | ១.៦២១ |
| ចំនួនខេត្ត-ក្រុង | ១២ | ១៧ | ២៤ | ២៤ | ២៤ | ២៤ |
| **ថវិកាវិភាជន៍** | | | | | | |
| MEF/រតនាគារជាតិ | ២០.០៣០ | ៦២.០០០ | ៥០.០០០ | ៥២.២៤៥ | ៤៥.០០០ | ២២៩.២៧៥ |
| អង្គភាពហិរញ្ញវត្ថុខេត្ត-ក្រុង | ៤៤.៩៤២ | ១៣៣.០៤០ | ៣៣៤.៦០២ | ៣៩១.៩៥៩ | ៣៩៥.០០០ | ១.២៩៩.៥៤៣ |
| **ថវិកាសរុប** | **៦៤.៩៧២** | **១៩៥.០៤០** | **៣៨៤.៦០២** | **៤៤៤.២០៤** | **៤៤០.០០០** | **១.៥២៨.៨១៨** |

## ៣.២ សហប្រតិបត្តិការបច្ចេកទេសសរុប : ឆ្នាំ ២០០១ - ២០០៥

ទីប្រឹក្សា និងអ្នកពិគ្រោះយោបល់របស់កម្មវិធីសិលា/PLG ដែលធ្វើការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង រតនាគារជាតិ និងជាមួយរតនាគារខេត្ត-ក្រុង បានគាំទ្រដល់ការបង្កើតលិខិតបទដ្ឋាន ការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្របណ្តុះបណ្តាល និង កម្មវិធីសិក្សាថ្នាក់ជាតិ និងក្នុងការរៀបចំបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងប្រព័ន្ធរបាយការណ៍។ តារាង៧ខាងក្រោមបង្ហាញថា របាយការណ៍ទៀងទាត់ ត្រូវបានផ្តល់ទៅអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ ។ ទីប្រឹក្សាហិរញ្ញវត្ថុចំនួន២៣នាក់ ត្រូវបានបញ្ជូនទៅថ្នាក់ខេត្ត-ក្រុង ដើម្បីធ្វើការគាំទ្រដល់មន្ទីរហិរញ្ញវត្ថុ និងរតនាគារខេត្ត-ក្រុងទាំង២៤ ។

| តារាង៧ : សហប្រតិបត្តិការបច្ចេកទេសរបស់កម្មវិធីសិលា/PLG ជាមួយ ក្រៃ និង រតនាគារជាតិ | | | | | | |
|---|---|---|---|---|---|---|
| ប្រភេទ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | សរុប |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | ៥០៩ | ១.២៨៣ | ១.៦២១ | ១.៦២១ | ១.៦២១ | ១.៦២១ |
| ចំនួនខេត្ត-ក្រុង | ១២ | ១៧ | ២៤ | ២៤ | ២៤ | ២៤ |
| **MEF/រតនាគារជាតិ** | | | | | | |
| ទីប្រឹក្សា/អ្នកពិគ្រោះយោបល់អន្តរជាតិ | ១,៧៥ | ០,២៥ | ០,២៥ | ០.២៥ | ០,២៥ | |
| ទីប្រឹក្សាជាតិ | ១ | ១ | ១ | ១ | ១ | |
| **ទីប្រឹក្សាសរុប** | **២,៧៥** | **១,២៥** | **១,២៥** | **១,២៥** | **១,២៥** | |
| **ចំណាយសរុប** | **៨២.០០០** | **៣៧.៣៥០** | **៣៧.៣៥០** | **៣៧.៣៥០** | **៣៧.៣៥០** | **២៣១.៤០០** |
| **អង្គភាពហិរញ្ញវត្ថុខេត្ត-ក្រុង** | | | | | | |
| ទីប្រឹក្សាជាតិសរុប | ១២ | ១៧ | ២០ | ២៣ | ២៣ | |
| **ចំណាយសរុប** | **៥៥.០០០** | **១៥៣.០០០** | **១៨០.០០០** | **២០៧.០០០** | **២០៧.០០០** | **៨០២.០០០** |
| ទីប្រឹក្សាសរុបរួម | **១៥** | **១៨** | **២១** | **២៤** | **២៤** | |
| ចំណាយសរុបរួម | **១៣៧.០០០** | **១៩០.៣៥០** | **២១៧.៣៥០** | **២៤៤.៣៥០** | **២៤៤.៣៥០** | **១.០៣៣.៤០០** |

## ៣.៣ សមិទ្ធិផលសំខាន់ៗ

### ៣.៣.១ គោលនយោបាយជាតិ លិខិតបទដ្ឋាន និង ប្រព័ន្ធ

ក្នុងឆមាសទី២នៃឆ្នាំ ២០០១ ទីប្រឹក្សាពិគ្រោះយោបល់បច្ចេកទេសPLG បានជួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំបង្កើតប្រព័ន្ធផ្ទេរថវិកាសំរាប់អន្តរស្ថាប័នរដ្ឋាភិបាល និងបានរៀបចំសេចក្តីព្រាងអនុក្រិត្យបង្កើតមូលនិធិឃុំ-សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត ។ ចាប់តាំងពីពេលនោះមក ដោយមានកិច្ចសហប្រតិបត្តិការជាមួយទីប្រឹក្សាហិរញ្ញវត្ថុគំរោងUNDP/DSP ទីប្រឹក្សាបច្ចេកទេស PLG បានជួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ ក្នុងការរៀបចំស្ទើរតែគ្រប់អនុក្រិត្យ ប្រកាស សេចក្តីសំរេច និងវិសោធនកម្ម ដែលពាក់ព័ន្ធនឹងនីតិវិធីមូលនិធិឃុំ-សង្កាត់ គំរូថវិកានិងប្លង់គណនី ប្រព័ន្ធគណនី ប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុ និងក្នុងការរៀបចំសេចក្តីណែនាំលទ្ធកម្ម ព្រមទាំងការរៀបចំការវិភាជន៍ មូលនិធិឃុំ-សង្កាត់ប្រចាំឆ្នាំផងដែរ ( សូមមើលក្នុងឧបសម្ព័ន្ធ២) ។

### ៣.៣.២ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងការកសាងសមត្ថភាព

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកម្មវិធីសិលាបានរៀបចំអោយមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដោយប្រើប្រាស់ធនាគារពាណិជកម្ម នៅថ្នាក់ខេត្ត-ក្រុង សំរាប់រាល់ការផ្ទេរសាច់ប្រាក់ជាដុល្លារអាមេរិក ។ ប្រព័ន្ធនេះនឹងត្រូវបានប្រើប្រាស់ជាបន្ត ដើម្បីគ្រប់គ្រងរាល់ការចំណាយគាំទ្រកម្មវិធី ដែលពាក់ព័ន្ធនឹងការផ្តល់សេវាគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងថវិការបស់មូលនិធិវិនិយោគខេត្ត-ក្រុង ដែលអនុវត្តដោយមន្ទីរវិស័យជុំវិញខេត្ត-ក្រុង។ តាមរយៈសិក្ខាសាលាជាតិ ដែលបានរៀបចំជាទៀងទាត់ ដោយមានគាំទ្រពីកម្មវិធីសិលា និងតាមរយៈការចូលរួមនៅក្នុងការប្រជុំប្រចាំខែរបស់រតនាគារ មានការគាំទ្រអោយមានការពិភាក្សាផ្លាស់ប្តូរយោបល់ និងសេចក្តីសំរេចលើវិធានការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ។ នៅទីបញ្ចប់ ដោយមានការគាំទ្រពីកម្មវិធីសិលា/PLG មន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ ក្នុងកិច្ចសហការជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បានរៀបចំកម្មវិធីបណ្តុះបណ្តាលហិរញ្ញវត្ថុ ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀត ដែលត្រូវបានរៀបចំនៅថ្នាក់ជាតិ ខេត្ត-ក្រុង និងឃុំ-សង្កាត់ ។

### ៣.៣.៣ ការគ្រប់គ្រងមូលនិធិឃុំ-សង្កាត់

កម្មវិធីសិលា/PLGបានផ្តល់ការគាំទ្រដ៏ទូលំទូលាយ ដល់អនុគណៈកម្មាធិការនានារបស់ NCSC លើការងារសារពើពន្ធ និងដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងរតនាគារជាតិ លើការងារមួយចំនួន

ពាក់ព័ន្ធទៅនឹងការកំណត់ក៏រិតមូលនិធិឃុំ-សង្កាត់ប្រចាំឆ្នាំ ការកំណត់រូបមន្តវិភាជន៍សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ ការកំណត់កាលវិភាគផ្ទេរមូលនិធិឃុំ-សង្កាត់ប្រចាំឆ្នាំពីគ្រប់ប្រភពធនធានទាំងអស់ ការកែសំរួលគំរូ និងនីតិវិធីគណនីសំរាប់សំរុះសំរួលការផ្ទេរថវិការបស់ម្ចាស់ជំនួយមួយចំនួនទៅគណនីឃុំ-សង្កាត់គោលដៅ ព្រមទាំងការងារដែលពាក់ព័ន្ធទៅនឹងគណនីថ្នាក់ជាតិ និងរបាយការណ៍នៃការផ្ទេរ និងការទូទាត់ជាទូទៅ ។

## ៤. ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងផែនការ

### ៤.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុសរុប : ឆ្នាំ ២០០១-២០០៥

ជារៀងរាល់ឆ្នាំ ធនធានរបស់កម្មវិធីសិលា/PLG ត្រូវបានវិភាជដល់ក្រសួងផែនការ និងមន្ទីរផែនការខេត្ត-ក្រុង ដើម្បីគាំទ្រដល់ការរៀបចំ ការបន្តពិនិត្យឡើងវិញ និងការពង្រឹងដល់ប្រព័ន្ធកសាងផែនការឃុំ-សង្កាត់ ប្រព័ន្ធទិន្នន័យឃុំ-សង្កាត់ និងដើម្បីគាំទ្រដល់ដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក-ខណ្ឌ ដើម្បីបញ្ចូលផែនការមូលដ្ឋានជាមួយនឹងផែនការខេត្ត-ក្រុង ។ ដូចបានរំលេចនៅក្នុងតារាង៨ ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ ថវិកាសរុបចំនួន ១៩៥.០០០ ដុល្លារអាមេរិក ត្រូវបានវិភាជន៍ដល់ក្រសួងផែនការ និងសរុបចំនួន ៦៨០.០០០ ដុល្លារអាមេរិក ដល់មន្ទីរផែនការខេត្ត/ក្រុង ដើម្បីគោលបំណងខាងលើ ។

| តារាង៨: ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងផែនការ | | | | | | |
|---|---|---|---|---|---|---|
| **ប្រភេទ** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | ៥០៩ | ១.២៨៣ | ១.៦២១ | ១.៦២១ | ១.៦២១ | ១.៦២១ |
| ចំនួនខេត្ត-ក្រុង | ១២ | ១៧ | ២៤ | ២៤ | ២៤ | ២៤ |
| **ថវិកាវិភាជន៍** | | | | | | |
| ក្រសួងផែនការ | ៣០.០០០ | ៣៥.០០០ | ៤៥.០០០ | ៤០.០០០ | ៤៥.០០០ | ១៩៥.០០០ |
| មន្ទីរផែនការខេត្ត-ក្រុង | ៣៦.៨៤៤ | ១០៩.០០០ | ១៥៣.៦៨៥ | ១៩៤.០២៣ | ១៩០.៥០០ | ៦៨៤.០៥១ |
| **ថវិកាសរុប** | ៦៦.៨៤៤ | ១៤៤.០០០ | ១៩៨.៦៨៥ | ២៣៤.០២៣ | ២៣៥.៥០០ | ៨៧៩.០៥១ |

### ៤.២ សហប្រតិបត្តិការបច្ចេកទេសសរុប : ឆ្នាំ ២០០១-២០០៥

ទីប្រឹក្សា និងអ្នកពិគ្រោះយោបល់បច្ចេកទេសកម្មវិធីសិលា/PLG ដែលធ្វើការជាមួយក្រសួងផែនការ និងមន្ទីរផែនការខេត្ត-ក្រុង បានគាំទ្រការបង្កើតលិខិតបទដ្ឋាន សេចក្តីណែនាំ និងប្រព័ន្ធទិន្នន័យកុំព្យូទ័រ

(software systems) ទាក់ទងទៅនឹងការរៀបចំផែនការឃុំ-សង្កាត់ និងសមាហរណកម្មថ្នាក់ស្រុក-ខណ្ឌ ។ ដូចបានរំលេចនៅក្នុងតារាង៩ខាងក្រោម ក្នុងកំឡុងពេល៥ឆ្នាំ សេវាប្រឹក្សាត្រូវបានផ្តល់ដល់ក្រសួងផែនការ និងមន្ទីរផែនការខេត្ត-ក្រុងទាំង២២ ដែលមានតំលៃសរុបប្រមាណ ៩៦០.០០០ ដុល្លារអាមេរិក ។

| តារាង៩: សហប្រតិបត្តិការបច្ចេកទេសរបស់កម្មវិធីសិលា/PLG ជាមួយក្រសួងផែនការ | | | | | | |
|---|---|---|---|---|---|---|
| **ប្រភេទ** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | ៥០៩ | ១.២៨៣ | ១.៦២១ | ១.៦២១ | ១.៦២១ | ១.៦២១ |
| ចំនួនខេត្ត-ក្រុង | ១២ | ១៧ | ២៤ | ២៤ | ២៤ | ២៤ |
| **ក្រសួងផែនការ** | | | | | | |
| ទីប្រឹក្សាអន្តរជាតិ | ១ | ០,៥ | ០,២៥ | ០,២៥ | ០,២៥ | |
| ទីប្រឹក្សាជាតិ | ១ | ១ | ១ | ០,៥ | ០,៥ | |
| **ទីប្រឹក្សាសរុប** | **២** | **១,៥** | **១,២៥** | **០,៧៥** | **០,៧៥** | |
| **តំលៃសរុប** | ៧០.០០០ | ៦២.០០០ | ៣៧.០០០ | ៣១.០០០ | ៣១.០០០ | ២៣១.០០០ |
| **មន្ទីរផែនការខេត្ត-ក្រុង** | | | | | | |
| ទីប្រឹក្សាជាតិ | ១០ | ១៥ | ២២ | ២២ | ២២ | |
| **តំលៃសរុប** | **៤៣.៨០០** | **១៣១.៤០០** | **១៨៣.៨៦០** | **១៨៣.៨៦០** | **១៨៣.៨៦០** | **៧២៧.០៨០** |
| ទីប្រឹក្សាសរុបរួម | **១២** | **១៧** | **២៣** | **២៣** | **២៣** | |
| ចំណាយសរុបរួម | **១១៣.៨០០** | **១៩៣.៤០០** | **២២០.៨៦០** | **២១៤.៨៦០** | **២១៤.៨៦០** | **៩៥៨.០៨០** |

## ៤.៣ សមិទ្ធិផលចំបងៗ

### ៤.៣.១ គោលនយោបាយជាតិ លិខិតបទដ្ឋាន និង ប្រព័ន្ធ

ក្នុងឆមាសទី២នៃឆ្នាំ ២០០១ ទីប្រឹក្សាបច្ចេកទេស PLG រួមជាមួយទីប្រឹក្សាពិគ្រោះយោបល់ GTZ បានជួយក្រសួងផែនការ ក្នុងការរៀបចំប្រព័ន្ធកសាងផែនការឃុំ-សង្កាត់ ដែលបន្ទាប់មកបានអនុម័តក្រោមក្របខ័ណ្ឌ NCSC ដោយអនុក្រិត្យអន្តរក្រសួង របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ។ ចាប់ពីពេលនោះមក ទីប្រឹក្សាPLG បានជួយ NCSC និងក្រសួងផែនការ ក្នុងការរៀបចំអនុក្រិត្យ ប្រកាស សេចក្តីសំរេច និងការធ្វើវិសោធនកម្មផ្សេងៗ ពាក់ព័ន្ធនឹងប្រព័ន្ធកសាងផែនការឃុំ-សង្កាត់ ។

### ៤.៣.២ ប្រព័ន្ធទិន្នន័យឃុំ-សង្កាត់ (CDB)

ដោយមានការគាំទ្របច្ចេកទេសពី PLG ក្រសួងផែនការបានបង្កើតប្រព័ន្ធទិន្នន័យជាតិមួយដែលមានសូចនាករតាមដានលើស្ថានភាពសេដ្ឋកិច្ច-សង្គម ។ ប្រព័ន្ធទិន្នន័យឃុំ-សង្កាត់ (CDB) គឺជាទិន្នន័យចំបងដែលឃុំ-សង្កាត់ប្រើប្រាស់ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍របស់ខ្លួន ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ប្រើទិន្នន័យនេះផងដែរ ដើម្បីគណនាអត្រាភាពក្រីក្រ សំរាប់ធ្វើការបែងចែកមូលនិធិឃុំ-សង្កាត់ប្រចាំឆ្នាំ ដល់ឃុំ-សង្កាត់។ លើសពីនេះ អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារផ្តល់ជំនួយផ្សេងៗទៀត ក៏បានប្រើប្រាស់ប្រព័ន្ធទិន្នន័យឃុំ-សង្កាត់នេះ (CDB) ជាប្រភពទិន្នន័យមួយ ដែលពាក់ព័ន្ធនឹងឃុំសង្កាត់-សង្កាត់ ។

### ៤.៣.៣ សមាហរណកម្មស្រុក-ខណ្ឌ និងប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ (CDPD)

ផ្អែកលើបទពិសោធន៍ទទួលបានពីកម្មវិធីសិលាដំណាក់កាលទី១ នៅឆ្នាំ២០០២ កម្មវិធីសិលា/PLG បានរៀបចំសេចក្តីណែនាំពីដំណើរការសមាហរណកម្មថ្នាក់ស្រុក-ខណ្ឌ សំរាប់អោយខេត្ត-ក្រុងសំរបសំរួលដំណើរការសមាហរណកម្ម និងបន្សុីគ្នា រវាងតំរូវការនិងគំរោងអាទិភាពរបស់ឃុំ-សង្កាត់ ជាមួយនឹងការគាំទ្រជាសក្តានុពលរបស់មន្ទីរវិស័យ និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ សេចក្តីណែនាំនេះត្រូវបានទទួលស្គាល់ជាផ្លូវការ ថាជាប្រកាស ដោយក្រសួងផែនការនៅឆ្នាំ២០០២ និងត្រូវបានពិនិត្យឡើងវិញក្នុងឆ្នាំ២០០៣ និង ២០០៤ជាបន្តបន្ទាប់ ដោយដាក់បញ្ចូលនូវមេរៀនដែលទទួលបានពីបទពិសោធន៍ក្នុងវគ្គនីមួយៗ។ តាមរយៈកិច្ចសហប្រតិបត្តិការ រវាង អង្គភាពរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ មន្ទីរផែនការ និងទីប្រឹក្សាPLG សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក-ខណ្ឌ ត្រូវបានរៀបចំធ្វើឡើងនៅក្នុងស្រុក-ខណ្ឌចំនួន១៨៥ ក្នុងខេត្ត-ក្រុងទាំង២៤ តាំងពីឆ្នាំ២០០២មក ។ តាមរយៈដំណើរការសមាហរណកម្មកម្មវិធី ដែលតែងតែត្រូវបានប្រារព្ធធ្វើឡើង ចន្លោះពីខែតុលា ដល់ ខែវិច្ឆិការៀងរាល់ឆ្នាំ ឃុំ-សង្កាត់បានចុះកិច្ចព្រមព្រៀង ជាមួយមន្ទីរវិស័យ និងអង្គការមិនមែនរដ្ឋាភិបាលនានា សំរាប់គាំទ្រនិងសហប្រតិបត្តិការនៅឆ្នាំបន្ទាប់។ ក្នុងឆ្នាំ ២០០២ កិច្ចព្រមព្រៀងច្រើនជាង៣០.០០០ ត្រូវបានចុះហត្ថលេខា ហើយក្នុងឆ្នាំ២០០៣ ចំនួនកិច្ចព្រមព្រៀងសរុបបានកើនឡើងជិតដល់ ៣៣.០០០។ ដើម្បីងាយស្រួលប្រមូល និងវិភាគ ថាតើកិច្ចព្រមព្រៀងទាំងនោះ ពាក់ព័ន្ធទៅនឹងតំរូវការអាទិភាពសំរាប់ការអភិវឌ្ឍន៍របស់ឃុំ-សង្កាត់ក៏រិតណានោះ ប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ (CDPD) ត្រូវបានរៀបចំបង្កើតឡើង។ ប្រព័ន្ធទិន្នន័យនេះត្រូវបានរៀបចំឡើងដោយPLG និងត្រូវបានដំណើរការនិងគ្រប់គ្រងដោយមន្ទីរផែនការខេត្ត-ក្រុងទាំង២៤ ក្នុងឆ្នាំ ២០០៤។

## ៥. ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ ក្រសួងអភិវឌ្ឍន៍ជនបទ

### ៥.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុសរុប : ឆ្នាំ ២០០១-២០០៥

ជារៀងរាល់ឆ្នាំ ធនធានរបស់កម្មវិធីសិលា/PLG ត្រូវបានវិភាជដល់ក្រសួងអភិវឌ្ឍន៍ជនបទ និង ផ្នែកគាំទ្របច្ចេកទេស (TSU) នៃគណៈកម្មាធិការប្រតិបត្តិខេត្ត-ក្រុង ដើម្បីគាំទ្រការរៀបចំ ការបន្តពិនិត្យ និងកែសំរួលឡើងវិញនូវសៀវភៅណែនាំការអនុវត្តន៍គំរោងរបស់ឃុំ-សង្កាត់ ការកសាងសមត្ថភាព ការតាមដាន ការត្រួតពិនិត្យរបស់ផ្នែកគាំទ្របច្ចេកទេស សេចក្តីណែនាំបច្ចេកទេស ប្លង់គំរូ និងការផ្តល់សេវាបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការរៀបចំនិងវិនិច្ឆ័យគំរោង ការអនុវត្តន៍ ការតាមដាន និងការថែទាំ។ ដូចបង្ហាញក្នុងតារាង១០ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ ថវិកាសរុបជិត ២០០.០០០ ដុល្លារអាមេរិក ត្រូវបានវិភាជដល់ក្រសួងអភិវឌ្ឍន៍ជនបទ និងសរុប ១,៦៦ លានដុល្លារអាមេរិក ដល់ផ្នែកគាំទ្របច្ចេកទេសនៅថ្នាក់ខេត្ត-ក្រុង សំរាប់គោលបំណងនេះ។

**តារាង១០: ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងអភិវឌ្ឍន៍ជនបទ**

| ប្រភេទ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | សរុប |
|---|---|---|---|---|---|---|
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | **៥០៩** | **១.២៨៣** | **១.៦២១** | **១.៦២១** | **១.៦២១** | **១.៦២១** |
| ចំនួនខេត្ត-ក្រុង | **១២** | **១៧** | **២៤** | **២៤** | **២៤** | **២៤** |
| **ថវិកាវិភាជន៍** | | | | | | |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១៧.៥០០ | ៤០.០០០ | ៤៥.០០០ | ៤៥.០០០ | ៤៥.០០០ | ១៩២.៥០០ |
| ផ្នែកគាំទ្របច្ចេកទេសខេត្ត-ក្រុង | ៧៥.២១៩ | ២៨០.២០៤ | ៤០៧.៦៧៧ | ៤៥០.៥១៧ | ៤៥០.០០០ | ១.៦៦៣.៦១៧ |
| **ថវិកាសរុប** | **៩២.៧១៩** | **៣២០.២០៤** | **៤៥២.៦៧៧** | **៤៩៥.៥១៧** | **៤៩៥.០០០** | **១.៨៥៦.១១៧** |

### ៥.២ សហប្រតិបត្តិការបច្ចេកទេសសរុប: ឆ្នាំ ២០០១-២០០៥

ទីប្រឹក្សាPLG និងទីប្រឹក្សាពិគ្រោះយោបល់មួយចំនួនផ្សេងទៀត ដែលធ្វើការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ខេត្ត-ក្រុង បានគាំទ្រដល់ការបង្កើតលិខិតបទដ្ឋាន សេចក្តីណែនាំជាច្រើន។ ដូចបង្ហាញនៅក្នុងតារាង១១ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ សេវាប្រឹក្សាត្រូវបានផ្តល់ដល់ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុងចំនួន២២ ដែលមានតំលៃសរុបចំនួន៩៧៨.០០០ ដុល្លារអាមេរិក។

| តារាង១១: សហប្រតិបត្តិការបច្ចេកទេសរបស់កម្មវិធីសិលា/PLG ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ | | | | | | |
|---|---|---|---|---|---|---|
| ប្រភេទ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | សរុប |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | **៥០៩** | **១.២៨៣** | **១.៦២១** | **១.៦២១** | **១.៦២១** | **១.៦២១** |
| ចំនួនខេត្ត-ក្រុង | **១២** | **១៧** | **២៤** | **២៤** | **២៤** | **២៤** |
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | | | | | | |
| ទីប្រឹក្សាអន្តរជាតិ | ១ | ១ | ១ | ០,៧៥ | ០ | |
| ទីប្រឹក្សាជាតិ | ១ | ១ | ១ | ១ | ១ | |
| **សរុបទីប្រឹក្សា** | **២** | **២** | **២** | **១,៧៥** | **១** | |
| **ចំណាយសរុប** | **៩៥.០០០** | **៦៩.៩០០** | **៦៩.៩០០** | **៤៩.៩០០** | **៩.៩០០** | **២៩៨.៦០០** |
| **ផ្នែកគាំទ្របច្ចេកទេសខេត្ត** | | | | | | |
| ទីប្រឹក្សាជាតិ | ១០ | ១៥ | ២១ | ២១ | ២១ | |
| **ចំណាយសរុប** | **៤០.០០០** | **១៣១.៤០០** | **១៨៣.៩៦០** | **១៨៣.៩៦០** | **១៨៣.៩៦០** | **៧២៣.២៨០** |
| **ទីប្រឹក្សាសរុបរួម** | **១២** | **១៧** | **២៣** | **២៣** | **២២** | |
| **ចំណាយសរុបរួម** | **៩៥.០០០** | **២០១.៣០០** | **២៥៣.៨៦០** | **២៣៣.៨៦០** | **១៩៣.៨៦០** | **៩៧៧.៨៨០** |

## ៥.៣ សមិទ្ធិផលសំខាន់ៗ

### ៥.៣.១ សេចក្តីណែនាំ និង បទដ្ឋានបច្ចេកទេស

**សៀវភៅណែនាំស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ-សង្កាត់** (PIM): សេចក្តីណែនាំសំរាប់ការអនុវត្តន៍គំរោងដែលគាំទ្រដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមកិច្ចសហការណ៍ ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ព្រមទាំងមានការប្រឹក្សានិងជំនួយការ ពីទីប្រឹក្សា PLG។ សេចក្តីណែនាំទាំងនេះ ត្រូវបានចងក្រងបញ្ចូលគ្នា ជាសៀវភៅណែនាំ ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ-សង្កាត់ (PIM) ហើយដែលបានអនុម័តដោយ NCSC កាលពីខែតុលា ឆ្នាំ២០០៣។ សៀវភៅ PIM នេះត្រូវបានពិនិត្យឡើងវិញរៀងរាល់ឆ្នាំ ក្នុងគោលបំណងកែលំអការទទួលខុសត្រូវ និងប្រសិទ្ធភាព។

**សៀវភៅណែនាំបច្ចេកទេស:** សៀវភៅណែនាំបច្ចេកទេសរបស់កម្មវិធីសិលា មានប្លង់ និងចំណុចបច្ចេកទេសលំអិត ដែលត្រូវអនុវត្តសំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដែលបានលើកឡើងដោយក្រុមប្រឹក្សាឃុំ-សង្កាត់។ សេចក្តីព្រាងនៃសៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងដោយទីប្រឹក្សាPLG

ក្រោមកិច្ចសហការណ៍ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ហើយត្រូវបានផ្សព្វផ្សាយ ដោយក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាធនធានមួយដ៏សំខាន់ សំរាប់ផ្នែកគាំទ្របច្ចេកទេស។ សៀវភៅណែនាំបច្ចេកទេសនេះ រួមជាមួយនឹង "កម្មវិធីប្លង់គំរូសិលា" ដែលត្រូវបានរៀបចំជាអេឡិចត្រូនិក ត្រូវបានប្រើប្រាស់ ដើម្បីរៀបចំគំរោង និងធ្វើការប៉ាន់តំលៃសំរាប់គំរោងមូលនិធិឃុំ-សង្កាត់ភាគច្រើន ហើយនៅមានភ្នាក់ងារផ្សេងៗជាច្រើនដែលអនុវត្តគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងប្រទេសកម្ពុជា ក៏បានប្រើប្រាស់ឧបករណ៍ទាំងនេះយ៉ាងទូលំទូលាយផងដែរ។

### ៥.៣.២ ការបង្កើតផ្នែកគាំទ្របច្ចេកទេស ការបណ្តុះបណ្តាល និងការបំពាក់សំភារៈ

ការងាររបស់ផ្នែកគាំទ្របច្ចេកទេស គឺ ការផ្តល់សេវាប្រឹក្សាបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ផ្នែកគាំទ្របច្ចេកទេសត្រូវបានបង្កើតឡើងក្នុងខេត្ត-ក្រុងទាំង២៤ នៅខែមីនា ឆ្នាំ២០០៣ តាមរយៈដំណើរការជ្រើសរើសមន្ត្រីដោយមានការប្រលងប្រជែង ដោយមានការគាំទ្រពី PLG ។ តាមរយៈការគាំទ្ររបស់កម្មវិធីសិលា/PLG ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសជាមូលដ្ឋានសំរាប់មន្ត្រីគាំទ្របច្ចេកទេសដែលទើបជ្រើសរើសថ្មី ដោយផ្តោតលើជំនាញដែលត្រូវការ ដើម្បីផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពដល់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ការបណ្តុះបណ្តាលដែលមានរយៈពេលពីរសប្តាហ៍ ចំនួន ៦វគ្គ ត្រូវបានផ្តល់ដល់មន្ត្រីគាំទ្របច្ចេកទេសចំនួនជាង១៥០នាក់។ ដើម្បីបំពេញបន្ថែមដល់ការបណ្តុះបណ្តាលផ្លូវការដែលបានធ្វើកន្លងមក ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធPLGខេត្ត-ក្រុង បានផ្តល់ការកសាងសមត្ថភាព ជាបន្តបន្ទាប់ដល់មន្ត្រីផ្នែកគាំទ្របច្ចេកទេស។ ផ្នែកគាំទ្របច្ចេកទេសទាំង២៤ខេត្ត-ក្រុង ត្រូវបានបំពាក់សំភារៈដូចជា កុំព្យូទ័រ ម៉ូតូ ឧបករណ៍បច្ចេកទេសជាមូលដ្ឋាន ដោយរាប់បញ្ចូលទាំងឧបករណ៍តូចៗ GPS ប្រើដោយដៃ និង ឧបករណ៍តេស្តដី និងបេតុង។

### ៥.៣.៣ ការតាមដានត្រួតពិនិត្យលើការអនុវត្តន៍គំរោងមូលនិធិឃុំ-សង្កាត់

តាមរយៈកិច្ចសហប្រតិបត្តិការរវាងកម្មវិធីសិលា/PLG និងក្រសួងអភិវឌ្ឍន៍ជនបទ មន្ត្រីផ្នែកគាំទ្របច្ចេកទេស ជារឿយៗ រួមជាមួយនឹងមន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បានធ្វើការតាមដានលើការអនុវត្តន៍ និងវដ្តនៃការអនុវត្តន៍គំរោង។ ក្រសួងអភិវឌ្ឍន៍ជនបទក៏បានធ្វើការសិក្សាជាក់លាក់មួយចំនួនទៅលើលទ្ធផលរបស់គំរោងដែលប្រើប្រាស់មូលនិធិឃុំ-សង្កាត់ ក្នុងវិស័យផ្លូវលំជនបទនិងការផ្គត់ផ្គង់ទឹកស្អាត ។ លទ្ធផលទទួលបានពីការតាមដានត្រួតពិនិត្យ និងការសិក្សាទាំងនេះ គឺមានប្រយោជន៍សំរាប់ធ្វើការកែលំអ

សេចក្តីណែនាំ លើវិស័យជាក់លាក់មួយចំនួន និងសំរាប់ពិនិត្យឡើងវិញ និងកែលំអប្រព័ន្ធអនុវត្តគំរោងតាមបែបវិមជ្ឈការ ។

## ៦. ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ ក្រសួងកិច្ចការនារី

### ៦.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុសរុប : ឆ្នាំ ២០០១-២០០៥

ជារៀងរាល់ឆ្នាំ ធនធានរបស់កម្មវិធីសិលា/PLG ត្រូវបានវិភាជដល់ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីខេត្ត-ក្រុង ដើម្បីគាំទ្រដល់ការរៀបចំ ការបន្តពិនិត្យឡើងវិញ និងការពង្រឹងយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្ត-ក្រុង និងឃុំ-សង្កាត់ ដូចជាការបណ្តុះបណ្តាលលើការយល់ដឹងពីយេនឌ័រ និងសកម្មភាពតាមដានត្រួតពិនិត្យ ដល់មន្ត្រីថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ ក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ-សង្កាត់ និងជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារឃុំ-សង្កាត់ ។ ដូចបានបង្ហាញក្នុងតារាង ១២ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ ថវិកាសរុប ១៩២.៥០០ ដុល្លារអាមេរិក ត្រូវបានវិភាជដល់ក្រសួងកិច្ចការនារី និងថវិកាសរុបជិត៩០០.០០០ ដុល្លារអាមេរិក ដល់មន្ទីរកិច្ចការនារីខេត្ត-ក្រុង សំរាប់គោលបំណងខាងលើ ។

| តារាង១២: ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងកិច្ចការនារី | | | | | | |
|---|---|---|---|---|---|---|
| **ប្រភេទ** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | **៥០៩** | **១.២៨៣** | **១.៦២១** | **១.៦២១** | **១.៦២១** | **១.៦២១** |
| ចំនួនខេត្ត-ក្រុង | **១២** | **១៧** | **២៤** | **២៤** | **២៤** | **២៤** |
| **ថវិកាវិភាជន៍** | | | | | | |
| ក្រសួងកិច្ចការនារី | ១៧.៥០០ | ៤០.០០០ | ៤៥.០០០ | ៤៥.០០០ | ៤៥.០០០ | ១៩២.៥០០ |
| មន្ទីរកិច្ចការនារីខេត្ត-ក្រុង | ៤៦.៩៤៦ | ១០៩.៦៩៥ | ១៥៥.៦៩៦ | ២១៦.០១៦ | ២២៨.០១៦ | ៧៥៦.៣៦៧ |
| **ថវិកាសរុប** | **៦៤.៤៤៦** | **១៤៩.៦៩៥** | **២០០.៦៩៦** | **២៦១.០១៦** | **២៧៣.០១៦** | **៩៤៨.៨៦៧** |

### ៦.២ សហប្រតិបត្តិការបច្ចេកទេសសរុប: ឆ្នាំ ២០០១-២០០៥

ទីប្រឹក្សាPLG និងទីប្រឹក្សាពិគ្រោះយោបល់មួយចំនួនផ្សេងទៀត ដែលធ្វើការជាមួយក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីខេត្ត-ក្រុង បានផ្តល់ការគាំទ្រជាបឋម សំរាប់ការបង្កើតយុទ្ធសាស្រ្តនានា កម្មវិធីបណ្តុះបណ្តាល និងនីតិវិធីបញ្ជ្រាបយេនឌ័រតាមរយៈក្របខ័ណ្ឌវិមជ្ឈការ ។ ដូចមានរំលេចនៅតារាង១៣ ខាងក្រោម ក្នុងរយៈពេល៥ឆ្នាំ សេវាប្រឹក្សាដោយផ្ទាល់ត្រូវបានផ្តល់ដល់ក្រសួង និងសេវាប្រឹក្សាពាក់កណ្តាល

ម៉ោងត្រូវបានផ្តល់ដល់មន្ទីរកិច្ចការនារីខេត្ត-ក្រុងទាំង២៤ ដែលមានថវិកាប្រមាណជា ៥០០.០០០ ដុល្លារអាមេរិក។

| តារាង១៣: សហប្រតិបត្តិការបច្ចេកទេសរបស់កម្មវិធីសិលា/PLG ជាមួយក្រសួងកិច្ចការនារី | | | | | | |
|---|---|---|---|---|---|---|
| **ប្រភេទ** | **២០០១** | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ការគ្របដណ្តប់** | | | | | | |
| ចំនួនឃុំ-សង្កាត់ | **៥០៩** | **១.២៨៣** | **១.៦២១** | **១.៦២១** | **១.៦២១** | **១.៦២១** |
| ចំនួនខេត្ត-ក្រុង | **១២** | **១៧** | **២៤** | **២៤** | **២៤** | **២៤** |
| **ក្រសួងកិច្ចការនារី** | | | | | | |
| ទីប្រឹក្សាអន្តរជាតិ | **០,៥** | **០,៥** | **១** | **០,៥** | **០,៥** | |
| ការគាំទ្រមន្ទីរនៅខេត្ត-ក្រុង | **៣,៦** | **៤.៥** | **៦** | **៦** | **៦** | |
| **ចំណាយសរុប** | **៦៥.២៤០** | **៨៧.៨០០** | **១៥០.៤០០** | **១០០.៤០០** | **១០០.៤០០** | **៥០៤.២៤០** |

## ៦.៣ សមិទ្ធិផលសំខាន់ៗ

### ៦.៣.១ លិខិតបទដ្ឋាន ប្រព័ន្ធ និង សេចក្តីណែនាំ

តាមរយៈសេវាប្រឹក្សា និងការគាំទ្រ ជាបន្តបន្ទាប់របស់ PLG ក្រសួងកិច្ចការនារី ក្រោមកិច្ចសហប្រតិបត្តិការណ៍ជាមួយក្រសួងមហាផ្ទៃ បានបង្កើតគោលនយោបាយណែនាំ និងសៀវភៅណែនាំបណ្តុះបណ្តាលជាច្រើន អំពីការបញ្ជ្រាបយេនឌ័រតាមរយៈក្របខ័ណ្ឌវិមជ្ឈការ។ ការគាំទ្រទាំងនេះ រួមមាន សេចក្តីណែនាំទៅខេត្ត-ក្រុង ដើម្បីជ្រើសរើស និងកសាងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារឃុំ-សង្កាត់ ការរៀបចំ និងចែកចាយសៀវភៅណែនាំស្តីអំពីទស្សនទានយេនឌ័រ តួនាទីនិងការទទួលខុសត្រូវរបស់ជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារឃុំ-សង្កាត់ និងការរៀបចំឧបករណ៍និងវិធីសាស្ត្រសំរាប់បញ្ជ្រាបយេនឌ័រ តាមរយៈដំណើរការកសាងផែនការឃុំ-សង្កាត់។

### ៦.៣.២ ការបណ្តុះបណ្តាល

ក្រសួងកិច្ចការនារីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រសួងដែលជាសមាជិកនៃ NCSC ដើម្បីបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ អំពីទស្សនទាននិងវិធីសាស្ត្រនៃការបញ្ជ្រាបយេនឌ័រ។ តាមរយៈកិច្ចសហប្រតិបត្តិការរវាងមន្ទីរកិច្ចការនារី និងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង គ្រូឧទ្ទេសទាំងនេះបានបន្តផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ជនបង្គោលទទួលបន្ទុកស្ត្រីនិង

កុមារឃុំ-សង្កាត់ និងសមាជិកគណៈកម្មាធិការកសាងផែនការនិងថវិកា ក្នុងខេត្ត-ក្រុងទាំង២៤។ តារាង១៤ ខាងក្រោម នឹងបង្ហាញដោយសង្ខេបនូវរាល់ការបណ្តុះបណ្តាលដែលក្រសួងកិច្ចការនារីបានអនុវត្ត ក្រោមការគាំទ្រថវិកា និងបច្ចេកទេស ពីកម្មវិធីសិលា/PLG ។

| តារាង១៤: ការគាំទ្រលើការបណ្តុះបណ្តាលយេនឌ័រ ដោយក្រសួងកិច្ចការនារី | | | | | |
|---|---|---|---|---|---|
| **លរ.** | **វគ្គបណ្តុះបណ្តាល** | **កាលបរិច្ឆេទ** | **ចំនួនសិក្ខាកាមសរុប** | | |
| | | | **ខេត្ត/ស្រុក** | **ឃុំ-សង្កាត់** | **សរុប** |
| | **២០០២** | | | | |
| ១ | ទស្សនទានយេនឌ័រនិងការតាមដានវាយតំលៃ | ឧសភា-ធ្នូ | ៨៩៦ | ៥.០៨៦ | **៥.៩៨២** |
| ២ | យេនឌ័រនិងអភិបាលកិច្ចល្អ | ឧសភា-ធ្នូ | ០ | ១៧៥ | **១៧៥** |
| ៣ | យេនឌ័រក្នុងការអភិវឌ្ឍន៍មូលដ្ឋាន | ឧសភា-ធ្នូ | ២៨៥ | ០ | **២៨៥** |
| ៤ | យេនឌ័រក្នុងជំនាញសំរបសំរួល | មិថុនា | ៩៥១ | ០ | **៩៥១** |
| | **២០០៣** | | | | |
| ៥ | យេនឌ័រក្នុងជំនាញសំរបសំរួល | មីនា | ៨៣០ | ០ | **៨៣០** |
| ៦ | យេនឌ័រ ជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ | កញ្ញា-ធ្នូ | ១.១២២ | ២.៥០៥ | **៣.៦២៧** |
| | **២០០៤** | | | | |
| ៧ | យេនឌ័រ ជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ | មេសា-មិថុនា | | ១.៦៣៧ | **១.៦៣៧** |
| ៨ | យេនឌ័រ ក្នុងការកសាងផែនការឃុំ-សង្កាត់ | មករា-ឧសភា | ១៧៨ | ៦.៤៣៧ | **៦.៦១៥** |

## ៧. ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### ៧.១ ការគាំទ្រផ្នែកហិរញ្ញវត្ថុសរុប : ឆ្នាំ ២០០១-២០០៥

កិច្ចសហការរវាងកម្មវិធីសិលា/PLG និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចាប់ផ្តើមជាផ្លូវការនៅក្នុងឆ្នាំ២០០៣។ ដូចមានរំលេចនៅតារាង១៥ ខាងក្រោម ក្នុងរយៈពេល៣ឆ្នាំ ការគាំទ្រគិតជាទឹកប្រាក់សរុបចំនួន១.៤៨លានដុល្លារអាមេរិក ត្រូវបានផ្តល់ដល់ថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ក្នុងក្របខ័ណ្ឌកម្មវិធីសិលា ហើយជំនួយបច្ចេកទេស ដែលគិតជាទឹកប្រាក់ចំនួន៣២៤.៥០០ដុល្លារអាមេរិក ត្រូវបានផ្តល់ដល់ថ្នាក់ខេត្ត-ក្រុង។

| តារាង១៥ : ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | |
|---|---|---|---|---|
| **ប្រភេទ** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
| **ថវិកាវិភាជន៍** | | | | |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ៤៨.៦១៦ | ៤០.៣៧៦ | **៨៨.៩៩២** |
| ការគាំទ្រដល់ខេត្ត-ក្រុង | ១០៣.៧៥៩ | ៤៨៥.០០០ | ៣៦០.០០០ | **៩៤៨.៧៥៩** |
| **ថវិកាសរុប** | **១០៣.៧៥៩** | **៥៣៣.៦១៦** | **៤០០.៣៧៦** | **១.០៣៧.៧៥១** |
| **សហប្រតិបត្តិការបច្ចេកទេស** | | | | |
| ទីប្រឹក្សាថ្នាក់ខេត្ត-ក្រុង | ៤ | ៤ | ៦ | |
| ចំណាយសរុប | ៩២.០០០ | ១០៤.០០០ | ១១៦.៥០០ | ២៧២.៥០០ |
| **ការគាំទ្រសរុប** | **១៩៥.៧៥៩** | **៦៣៧.៦១៦** | **៥១៦.៨៧៦** | **១.៣១០.២៥១** |

## ៧.២ សមិទ្ធផលសំខាន់ៗ

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់កម្មវិធីសិលា ក្នុងការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៅថ្នាក់ខេត្ត-ក្រុង និងឃុំ-សង្កាត់ ព្រមទាំងការដោះស្រាយបញ្ហាគ្រប់គ្រងដីធ្លី កម្មវិធីសិលាបានធ្វើកិច្ចសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចាប់តាំងពីឆ្នាំ២០០៣មក លើការងារមួយចំនួន ដូចខាងក្រោម :

**ផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម:** ដើម្បីគាំទ្រដល់ការខិតខំប្រឹងប្រែងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការកែលំអជាបន្ត នូវវិធីសាស្ត្រផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនៅក្នុងបរិបទរបស់ឃុំ ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសរបស់កម្មវិធីសិលា/PLG កំពុងត្រូវបានផ្តល់អោយខេត្តចំនួន៨ ដោយផ្តោតលើការបង្កើនចំនួនឃុំគោលដៅ ក្នុងឆ្នាំ ២០០៣ ។ ការគាំទ្រត្រូវបានផ្តល់ទៅអោយក្រសួង មន្ទីរខេត្ត-ក្រុង និងការិយាល័យស្រុក ព្រមទាំងឃុំគោលដៅផងដែរ ។

**ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច :** យោងតាមច្បាប់ភូមិបាល កម្មវិធីសិលា/PLG និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងសហការគ្នាលើសកម្មភាពសាកល្បងចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍ ក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ ក្រុមការងារទទួលបន្ទុកលើការងារសាកល្បងចុះបញ្ជីកម្មសិទ្ធិដីធ្លីជនជាតិដើមភាគតិច ត្រូវបានបង្កើតឡើងនៅក្នុងខេត្តទាំងពីរនេះ។

**ការផ្សព្វផ្សាយច្បាប់ភូមិបាលដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ :** ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវដោះស្រាយជាញឹកញាប់នូវជម្លោះដីធ្លីដែលកើតមានឡើងនៅមូលដ្ឋាន ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ជាច្រើនបានទទួលស្គាល់នូវភាពចាំបាច់ ក្នុងការផ្សព្វផ្សាយអោយបានប្រសើរជាងមុន នូវច្បាប់ភូមិបាល រួមទាំងតួនាទីជាក់លាក់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងការកសាងផែនការឃុំ-សង្កាត់របស់ខ្លួន ។ ការវិភាជន៍មូលនិធិវិនិយោគខេត្ត-ក្រុងប្រចាំឆ្នាំរបស់កម្មវិធីសិលា ដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងខេត្តចំនួន១២-១៤ ក្នុងមួយឆ្នាំៗ បានជួយអោយមន្ទីរទាំងនោះ អាចឆ្លើយតបទៅនឹងតំរូវការនេះ នៅថ្នាក់មូលដ្ឋានបាន ។

## ៨. ការគាំទ្រថវិការបស់កម្មវិធីសិលា/PLG ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់

### ៨.១ ការគាំទ្ររបស់កម្មវិធីសិលា/PLG ដល់មូលនិធិឃុំ-សង្កាត់

ចាប់តាំងពីមូលនិធិឃុំ-សង្កាត់ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលក្នុងឆ្នាំ២០០២មក ជំនួយពីខាងក្រៅទាំងអស់សំរាប់មូលនិធិនេះ ត្រូវបានធ្វើឡើងតាមរយៈកម្មវិធីសិលា/PLG ។ ដូចមានរំលេចនៅតារាង១៦ខាងក្រោម ក្នុងរយៈពេល៣ឆ្នាំ ចាប់តាំងពីមូលនិធិឃុំ-សង្កាត់ត្រូវបានដាក់អោយដំណើរការ និងរួមទាំងការធានាសន្យាសំរាប់ឆ្នាំ២០០៥នេះផងដែរ គឺមានទឹកប្រាក់ទាំងអស់សរុបចំនួន ២០.៦ លានដុល្លារអាមេរិក ត្រូវបានផ្តល់ដល់មូលនិធិឃុំ-សង្កាត់ ។ ទឹកប្រាក់ទាំងនេះរួមបញ្ចូលទាំង ជំនួយឥតសំណងប្រចាំឆ្នាំពីគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន (PLG) របស់អង្គការសហប្រជាជាតិ និងការទូទាត់ពីគំរោងវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋាន (RILG) ដែលប្រើប្រាស់កម្ចីរបស់ធនាគារពិភពលោកផងដែរ ។ បើធៀបទៅលើធនធានសរុបចំនួន ៥១.៥លានដុល្លារអាមេរិក នៃមូលនិធិឃុំ-សង្កាត់សំរាប់រយៈពេល៤ឆ្នាំ យើងឃើញថា ទឹកប្រាក់សរុបខាងលើ គឺស្មើនឹង ៤០ % ។

**តារាង១៦ : ការរួមចំណែករបស់កម្មវិធីសិលា/PLG ដល់មូលនិធិឃុំ-សង្កាត់**

| | **២០០២** | **២០០៣** | **២០០៤** | **២០០៥** | **សរុប** |
|---|---|---|---|---|---|
| **កម្មវិធីសិលា/PLG** | ១.៤០០.០០០ | ២.០០០.០០០ | ២.០០០.០០០ | ២.០០០.០០០ | **៧.៤០០.០០០** |
| **កម្មវិធីសិលា/ WB-RILG** | | ៣.៨០០.០០០ | ៤.៧០០.០០០ | ៤.៧០០.០០០ | **១៣.២០០.០០០** |
| **សរុប** | **១.៤០០.០០០** | **៥.៨០០.០០០** | **៦.៧០០.០០០** | **៦.៧០០.០០០** | **២០.៦០០.០០០** |

### ៨.២ ការគាំទ្រថវិការបស់កម្មវិធីសិលា/PLG ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់គោលដៅ

គំរោងមួយចំនួនដែលអនុវត្តនៅក្នុងក្របខ័ណ្ឌកម្មវិធីសិលា ការវិភាជន៍ទុនវិនិយោគផ្សេងៗទៀតត្រូវបានអនុវត្តសំរាប់ឃុំ-សង្កាត់គោលដៅ បន្ថែមលើការវិភាជន៍មូលនិធិឃុំ-សង្កាត់ ។ ដូចមានរំលេចនៅ

តារាង១៧ខាងក្រោម គំរោងការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថានរបស់ដានីដា (NREM) នៅក្នុងខេត្តចំនួន៦ និងគំរោងកាត់បន្ថយភាពក្រីក្រនៅជនបទ និង ការអភិវឌ្ឍន៍សហគមន៍ជនបទ របស់មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម (IFAD RPRP/CBRD) នៅក្នុងខេត្តចំនួន៤ ទឹកប្រាក់សរុបចំនួន ២.១៦លានដុល្លារអាមេរិក ត្រូវបានវិភាជដល់ឃុំគោលដៅ ដើម្បីបង្កើនធនធានវិនិយោគសំរាប់សកម្មភាពអភិវឌ្ឍន៍ ។

| តារាង១៧ : ការវិភាជន៍របស់កម្មវិធីសិលា/PLG ដល់ឃុំ-សង្កាត់គោលដៅ | | | |
|---|---|---|---|
| **គំរោងរបស់អ្នកផ្តល់ជំនួយ** | **២០០៤** | **២០០៥** | **សរុប** |
| **កម្មវិធីសិលា/NREM** | ៧០.០០០ | ៩៦.០០០ | **១៦៦.០០០** |
| **កម្មវិធីសិលា/IFAD RPRP/CBRD** | ៣៩៨.០០០ | ១.៦០០.០០០ | **១.៩៩៨.០០០** |
| **សរុប** | **៤៦៨.០០០** | **១.៦៩៦.០០០** | **២.១៦៤.០០០** |

## ៩. សំភារៈ និង សំណង់អគាររដ្ឋបាល

### ៩.១ សំណង់អគាររដ្ឋបាល

ដោយមានការកើននៃការទទួលខុសត្រូវ នៅក្នុងក្របខ័ណ្ឌនៃកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល សាលាខេត្ត-ក្រុងភាគច្រើនបំផុត បានជួបប្រទះនឹងការលំបាក ដោយសារសភាពចាស់ទ្រុឌទ្រោមនិងមិនមានការិយាល័យគ្រប់គ្រាន់សំរាប់បំពេញការងារ ។ ដូចមានរំលេចនៅក្នុងតារាង១៨ ខាងក្រោម ធនធានដែលកៀងគរបានក្នុងក្របខ័ណ្ឌកម្មវិធីសិលា បានជួយអោយមានការសាងសង់សំណង់អគាររដ្ឋបាលថ្មីចំនួន១០ និងការកែលំអឡើងវិញនូវអគារចំនួន១២ផ្សេងទៀតនៅក្នុងបរិវេណសាលាខេត្ត-ក្រុង ។ ការរួមចំណែករបស់កម្មវិធីសិលា មានទឹកប្រាក់សរុបចំនួន ៤៨៥.០០០ ដុល្លារអាមេរិក ហើយទឹកប្រាក់បន្ថែមជាមធ្យម២០%ទៀត ត្រូវបានកៀងគរពីថវិកាសាលាខេត្ត-ក្រុង ។

| តារាង១៨ : ការគាំទ្រផ្នែកសំណង់អគាររដ្ឋបាល | | | |
|---|---|---|---|
| **អគារ** | **ខេត្ត-ក្រុង** | **តំលៃសរុប** | **តំលៃមធ្យម** |
| សាងសង់ថ្មី | ១០ | ៣៦៥.០០០ | ៣៦.៥០០ |
| កែលំអឡើងវិញ | ១២ | ១២០.០០០ | ១០.០០០ |
| **សរុប** | **២២** | **៤៨៥.០០០** | |

## ៩.២ សំភារៈ

ការផ្គត់ផ្គង់មធ្យោបាយធ្វើដំណើរនិងសំភារៈការិយាល័យ ដល់ក្រសួងដែលជាសមាជិកនៃ NCSC ហើយជាពិសេស ដល់មន្ត្រីស៊ីវិល នៅថ្នាក់ខេត្ត-ក្រុង និងស្រុក-ខណ្ឌ ដែលទទួលបន្ទុកផ្ដល់ការគាំទ្រ ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាមូលដ្ឋានគ្រឹះ សំរាប់ការងារបណ្ដុះបណ្ដាល ការតាមដានត្រួតពិនិត្យ របាយការណ៍ និងការងារគ្រប់គ្រងទូទៅផ្សេងៗទៀត។ ពិនិត្យជារួម តារាង១៩ ឆ្លុះបញ្ចាំងអោយឃើញពី ប្រភេទសំភារៈសំខាន់ៗ ដែលកម្មវិធីសិលាបានទិញ និងបែងចែកទៅអោយក្រសួង និងខេត្ត-ក្រុង សំរាប់ប្រើប្រាស់ ក្នុងការផ្ដល់សេវាគាំទ្រ ក្នុងអណត្តិរបស់ NCSC ។

| តារាង១៩ : ការគាំទ្រផ្នែកសំភារៈ | | | |
|---|---|---|---|
| **សំភារៈ** | **ចំនួន** | **តំលៃមធ្យម** | **តំលៃសរុប** |
| រថយន្ត | ៣២ | ១៨.០០០ | ៥៧៦.០០០ |
| ទោចក្រយន្ត | ៩២៣ | ១.១០០ | ១.០១៥.៣០០ |
| កុំព្យូទ័រ | ២១៨ | ៩០០ | ១៩៦.២០០ |
| ម៉ាស៊ីនថតចម្លង | ៤៨ | ៣.០០០ | ១៤៤.០០០ |
| **សរុប** | | | **១.៩៣១.៥០០** |

## ១០. សេចក្ដីសង្ខេប

ឧបសម្ព័ន្ធ១ នៅទំព័របន្ទាប់ គឺជាតារាងសង្ខេប បង្ហាញពីការគាំទ្រសរុបពីម្ចាស់ជំនួយ តាមរយៈក្របខ័ណ្ឌកម្មវិធីសិលា ដើម្បីអោយ NCSC អាចសម្រេចបានអណត្តិរបស់ខ្លួន ។ ដូចដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធនោះ ជំនួយសរុបមានទឹកប្រាក់ចំនួន ៤៤ លានដុល្លារអាមេរិក :

- ៧៨% ត្រូវបានផ្ទេរជាថវិកាគាំទ្រ ដល់ក្រសួងទាំង៦ ដែលជាសមាជិក NCSC និងមន្ទីរជំនាញខេត្ត-ក្រុង/អង្គភាព នៅក្នុងខេត្ត-ក្រុងទាំង២៤ ដែលទទួលបន្ទុកអនុវត្តក្របខ័ណ្ឌច្បាប់វិមជ្ឈការ ។
- ១៦% សំរាប់ចំណាយលើសេវាប្រឹក្សា ដល់ក្រសួងទាំង៦ ដែលជាសមាជិក NCSC និងមន្ទីរជំនាញខេត្ត-ក្រុង/អង្គភាព នៅក្នុងខេត្ត-ក្រុងទាំង២៤ ។
- ៥% ត្រូវបានបែងចែកសំរាប់ការធ្វើលទ្ធកម្មសំភារៈនៅថ្នាក់ជាតិនិងខេត្ត-ក្រុង និងសំរាប់សំណង់អគាររដ្ឋបាលនៅសាលាខេត្ត-ក្រុង ដែលត្រូវប្រើប្រាស់សំរាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ពាក់ព័ន្ធនឹងកំរិតទាំងបីនៃក្របខ័ណ្ឌថវិការបស់រាជរដ្ឋាភិបាល :

- ៧% ត្រូវបានគ្រោងសំរាប់ថ្នាក់ជាតិ
- ៤១% ត្រូវបានគ្រោងសំរាប់គាំទ្រថ្នាក់ខេត្ត-ក្រុង
- ៥២% ត្រូវបានគ្រោងសំរាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

សេជនួយ

សិលា/PLG

## ឧបសម្ព័ន្ធ១ : ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដែលបានផ្តល់អោយ NCSC តាមរយៈកម្មវិធីសិលា/PLG : ឆ្នាំ ២០០១-២០០៥

| | គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ (NCSC) | | | | | |
|---|---|---|---|---|---|---|
| | ក្រសួងដែលជាសមាជិកនៃ NCSC | | | | | |
| | មហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ផែនការ | អភិវឌ្ឍន៍ជនបទ | កិច្ចការនារី | រៀបចំដែនដី |
| ថវិកាគាំទ្រ | ៥៣០.០០០ | ២២៩.២៧៥ | ១៩៥.០០០ | ១៩២.៥០០ | ១៩២.៥០០ | ៨៨.៩៩២ |
| ការគាំទ្របច្ចេកទេស | ៧៥៩.០០០ | ២៣១.៤០០ | ២៣១.០០០ | ២៥៤.៦០០ | ៣០០.០០០ | |
| **សរុបរង** | **១.២៨៩.០០០** | **៤៦០.៦៧៥** | **៤២៦.០០០** | **៤៤៧.១០០** | **៤៩២.៥០០** | **៨៨.៩៩២** |

| | មន្ទីរជំនាញជុំវិញខេត្ត-ក្រុង/អង្គភាពខេត្ត-ក្រុង | | | | | |
|---|---|---|---|---|---|---|
| | អង្គភាពរដ្ឋបាលមូលដ្ឋាន | ហិរញ្ញវត្ថុ | មន្ទីរផែនការ | ផ្នែកគាំទ្របច្ចេកទេស | មន្ទីរកិច្ចការនារី | មន្ទីររៀបចំដែនដី |
| ថវិកាគាំទ្រ | ៤.៩៣៦.៧៤៤ | ១.២៩៩.៥៤៣ | ៦៨៤.០៥១ | ១.៦៦៣.៦១៧ | ៧៥៦.៣៦៧ | ៩៤៨.៧៥៩ |
| ការគាំទ្របច្ចេកទេស | ៣.១៩៧.០០០ | ៨០២.០០០ | ៧២៧.០៨០ | ៧២៣.២៨០ | ២០៤.២៤០ | ២៧២.៥០០ |
| **សរុបរង** | **៨.១៣៣.៧៤៤** | **២.១០១.៥៤៣** | **១.៤១១.១៣១** | **២.៣៨៦.៨៩៧** | **៩៦០.៦០៧** | **១.២២១.២៥៩** |
| **សរុបរួម** | **៩.៤១៨.៧៤៤** | **២.៥៦២.២១៨** | **១.៨៣៧.១៣១** | **២.៨៣៣.៩៩៧** | **១.៤៥៣.១០៧** | **១.៣១០.២៥១** |

| | | ក្រុមប្រឹក្សាឃុំ-សង្កាត់ |
|---|---|---|
| ថវិកាគាំទ្រ | | ២២.៧៦៤.០០០ |

| សង្ខេប | | | | | |
|---|---|---|---|---|---|
| ប្រភេទ | ថ្នាក់ជាតិ | ថ្នាក់ខេត្ត-ក្រុង | ថ្នាក់ឃុំ-សង្កាត់ | សរុប | % |
| ថវិកាគាំទ្រ | ១.៤២៨.២៦៧ | ១០.២៨៩.០៨១ | ២២.៧៦៤.០០០ | ៣៤.៤៨១.៣៤៨ | ៧៧% |
| ការគាំទ្របច្ចេកទេស | ១.៧៧២.០០០ | ៥.៩២៦.១០០ | | ៧.១៩០.១០០ | ១៧% |
| សំភារៈ | | ១.៩៣១.៥០០ | | ១.៩៣១.៥០០ | ៤% |
| សំណង់អគារ | | ៤៨៥.០០០ | | ៤៨៥.០០០ | ១% |
| **សរុប** | **៣.២០០.២៦៧** | **១៨.៦៣១.៦៨១** | **២២.៧៦៤.០០០** | **៤៤.៩៩៥.៩៤៨** | **១០០%** |
| **ភាគរយ (%)** | **៧%** | **៤២%** | **៥១%** | **១០០%** | |

## ឧបសម្ព័ន្ធ II: ការគាំទ្រផ្នែកក្របខ័ណ្ឌច្បាប់ របស់កម្មវិធីសិលា/PLG ដល់ គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់

| ល.រ | កាលបរិច្ឆេទ | លេខ | ក្របខ័ណ្ឌច្បាប់/ឯកសារ |
|---|---|---|---|
| **តួនាទី មុខងារ និងអំណាច របស់ក្រុមប្រឹក្សាឃុំ សង្កាត់** | | | |
| | 12/12/01 | ១៣០៦ ប្រក | ប្រកាស ស្តីពីការជ្រើសរើសមន្ត្រីរដ្ឋបាលមូលដ្ឋានសំរាប់ ១៧ ខេត្ត-ក្រុង |
| | 04/01/02 | ០០៤ គ.ជ.ន.ស | សេចក្តីណែនាំ ស្តីពីភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដែលឈរឈ្មោះបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងដំណាក់កាលអន្តរកាល |
| | 06/02/02 | ០៩៧ ប្រក | ប្រកាស ស្តីពីការណែនាំជ្រើសរើសមន្ត្រីបង្គោលនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត-ក្រុង |
| | 18/02/02 | ០០៣ សណន | សេចក្តីណែនាំ ស្តីពីការរៀបចំកិច្ចប្រជុំលើកដំបូងដើម្បីប្រកាសសុពលភាពសមាជិករបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និង ប្រកាស ឈ្មោះប្រធានក្រុមប្រឹក្សាឃុំ - សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ព្រមទាំងការចាប់ផ្តើមបំពេញការងារ បន្ទាប់ពីកិច្ចប្រជុំលើកដំបូង |
| | 18/02/02 | ០០៣ សណន | សេចក្តីណែនាំ ស្តីពីការចាប់ផ្តើមបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ បន្ទាប់ពីកិច្ចប្រជុំលើកដំបូង |
| | 18/02/02 | ០០៤ សណន | សេចក្តីណែនាំ ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ |
| | 25/03/02 | ២២ អនក្រ.បក | អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ |
| | 18/04/02 | ១៨៨៤ ប្រក | ប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត-ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ |
| | 07/05/02 | ១៩៥០ ប្រក | ប្រកាស ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| ) | 22/12/02 | ១៣២៧ សណន | សេចក្តីណែនាំ ស្តីពីតារាងតាមដានការអនុវត្តន៍គោលនយោបាយវិមជ្ឈការឃុំ សង្កាត់ |

| | | | |
|---|---|---|---|
| 1 | 05/02/03 | ១៤៣ សណន | ប្រកាស ស្តីពីទម្រង់របាយការណ៍ឆ្នាំគំរោងឃុំ សង្កាត់ ២០០២ និងទម្រង់របាយការណ៍ប្រចាំខែ ២០០៣ |
| 2 | 13/06/03 | ០០៥ សណន | សេចក្តីណែនាំ ស្តីពីការជ្រើសរើសជនបង្គោលទទួលបន្ទុកការងារតាមដាន និងវាយតំលៃគំរោងមូលនិធិឃុំ-សង្កាត់ |
| 3 | 22/07/03 | ៦៤៨ សណន | សេចក្តីណែនាំ ស្តីពីទម្រង់របាយការណ៍របស់អង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្ត ក្រុង |
| 4 | 06/01/04 | ០០៤ សណន | សេចក្តីណែនាំ ស្តីពីការជ្រើសរើសមន្ត្រីរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុងបន្ថែមមួយចំនួនទៀត |
| 5 | 21/04/04 | ០០៤ សណន | សេចក្តីណែនាំ ស្តីពីរបៀបដំណើរការជ្រើសរើស និងការកំណត់អំពីរបៀបរបបធ្វើការងារ ព្រមទាំងការបែងចែក ការទទួលខុសត្រូវក្នុងការបំពេញភារកិច្ច របស់មន្ត្រីបង្គោលរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង |
| 6 | 16/07/04 | ៩៤០ ប្រក | ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង |
| 7 | 14/09/04 | ១៧១ សណន | សេចក្តីណែនាំ ស្តីពីការកែសំរួលទំរង់របាយការណ៍ប្រចាំឆ្នាំ និងប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ |
| 8 | 11/11/04 | ១០០ សណន | សៀវភៅណែនាំ ស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់លើការងារអភិវឌ្ឍន៍មូលដ្ឋាន |

## ឧបសម្ព័ន្ធ II: ការគាំទ្រផ្នែកក្របខ័ណ្ឌច្បាប់ របស់កម្មវិធីសិលា និង PLG ដល់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

| បរ | កាលបរិច្ឆេទ | លេខ | ក្របខ័ណ្ឌច្បាប់/ឯកសារ |
|---|---|---|---|
| I. កសាងផែនការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ឃុំ សង្កាត់ | | | |
| | 07/02/02 | ៩៨ ប្រក | ប្រកាសអន្តរក្រសួង ស្តីពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
| | 04/04/02 | ៥៩ ប្រក | ប្រកាសអន្តរក្រសួង ស្តីពីគោលការណ៍ណែនាំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
| | 26/08/02 | ២៤ ប្រក | ប្រកាសអន្តរក្រសួង ស្តីពីកែសំរួលមាត្រា ២៩ របស់ប្រកាសអន្តរក្រសួង ស្តីពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ លេខ ៩៨ |
| | 26/08/02 | ០៦៦ ប្រក | ប្រកាស ស្តីពីការរៀបចំប្រព័ន្ធផែនការគាំទ្រខេត្ត ក្រុង ដើម្បីគាំទ្រផែនការឃុំ សង្កាត់ |
| | 09/09/02 | ១៤៦ ផក | សេចក្តីណែនាំបច្ចេកទេស សំរាប់ការរៀបចំដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក |
| | 17/07/03 | ផក | ឯកសារណែនាំបច្ចេកទេស សំរាប់អ្នកសំរបសំរួលដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ |
| | 27/07/03 | ១៥០ ផក | សេចក្តីណែនាំ ស្តីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ |
| | 08/09/03 | ០៨៧ សណន | សេចក្តីណែនាំ ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ សង្កាត់ |
| | 22/09/03 | ៦៨០ ផក | សេចក្តីណែនាំបច្ចេកទេស សំរាប់ការរៀបចំដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក ឆ្នាំ ២០០៣ |
| 0 | 01/2004 | សណន | សៀវភៅណែនាំសង្ខេប ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ សង្កាត់ |
| 1 | 07/07/04 | ០៦៩ សណន | សេចក្តីណែនាំ ស្តីពីដំណើរការរៀបចំកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ |
| 2 | 04/11/04 | ៣០៤ ផក | សេចក្តីណែនាំបច្ចេកទេស សំរាប់ការរៀបចំដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក ឆ្នាំ ២០០៤ |

## ឧបសម្ព័ន្ធ II: ការគាំទ្រផ្នែកក្របខ័ណ្ឌច្បាប់របស់កម្មវិធីសិលា និង PLG ដល់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

| លរ. | កាលបរិច្ឆេទ | លេខ | ក្របខ័ណ្ឌច្បាប់/ឯកសារ |
|---|---|---|---|
| **III. កិច្ចការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់** | | | |
| 1 | 15/10/01 | សហវ.ប្រក. | ប្រកាស ស្តីពីការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០២ |
| 2 | 25/02/02 | ១៦ អនក្រ.បក | អនុក្រឹត្យ ស្តីពីមូលនិធិឃុំ សង្កាត់ |
| 3 | 02/04/02 | ២៦ អនក្រ.បក | អនុក្រឹត្យ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ |
| 4 | 10/04/02 | ២៥០ សហវ.ប្រក.រជ | ប្រកាស ស្តីពីការបង្កើតប្រព័ន្ធគណនីនៃគណនេយ្យថវិកាឃុំ សង្កាត់ |
| 5 | 25/04/02 | ៣២៩ សហវ.ប្រក. | ប្រកាស ស្តីពីទំរង់ និងមាតិកាថវិកាឃុំ សង្កាត់ |
| 6 | 29/04/02 | ៣៣១ សហវ.ប្រក. | ប្រកាសណែនាំ ស្តីពីការរៀបចំ និងការអនុវត្តន៍ថវិកាឃុំ សង្កាត់ |
| 7 | 24/06/02 | ៦១ អនក្រ.បក | អនុក្រឹត្យ ស្តីពីការកំណត់ប្រាក់បំណាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ |
| 8 | 24/06/02 | ៦២ អនក្រ.បក | អនុក្រឹត្យ ស្តីពីការកំណត់ថ្លៃជាងក្រដាសអត្រានុកូលដ្ឋាន និងតែមប្រើសារពើពន្ធ |
| 9 | 27/06/02 | ៦១៨ សណន | ប្រកាសណែនាំ ស្តីពីការតែងតាំងបេឡាករបុរេប្រទាន និងភ្នាក់ងារប្រមូលចំណូលសំរាប់ឃុំ សង្កាត់ |
| 10 | 29/07/02 | ៣៦៥៩ សហវ.ប្រក. | ប្រកាស ស្តីពីការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់បន្ថែមដល់ក្រុមប្រឹក្សាឃុំ សង្កាត់សំរាប់ឆ្នាំ២០០២ |
| 11 | 04/09/02 | ០១០ សណន | ប្រកាស ស្តីពីការបើកប្រាក់បៀវត្សជូនស្មៀនឃុំ សង្កាត់ ស្មៀន ប្រាក់ឧបត្ថម្ភជូនក្រុមប្រឹក្សាឃុំ សង្កាត់និង ប្រាក់ឧបត្ថម្ភប្រធានភូមិ |

| | | | |
|---|---|---|---|
| 12 | 18/09/02 | ០១១ សហណ | សេចក្តីណែនាំ ស្តីពីការបំពេញល័ក្ខខ័ណ្ឌ ដើម្បីទទួលបានធនធានមូលនិធិឃុំ សង្កាត់ សំរាប់ការផ្ទេរលើកទីបី ក្នុងឆ្នាំ ២០០២ |
| 13 | 13/12/02 | ៦៩៧២ សហវ.ប្រក. | ប្រកាស ស្តីពីការវិភាជន៍បន្ថែមធនធានមូលនិធិឃុំ សង្កាត់ជូនក្រុមប្រឹក្សាឃុំ សង្កាត់សំរាប់ឆ្នាំ២០០២ |
| 14 | 24/12/02 | ៦៧៧៨ សហវ.ប្រក. | ប្រកាស ស្តីពីការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ដល់ឃុំ សង្កាត់សំរាប់ឆ្នាំ២០០៣ |
| 15 | 31/12/02 | ៩៣៨ សហវ. | ប្រកាសណែនាំ ស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់ |
| 16 | 31/12/02 | ៩៣៧ សហវ. | ប្រកាសណែនាំ ស្តីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់ |
| 17 | 05/02/03 | ៤៣២ សហវ.ថហ. | ប្រកាស ស្តីពីការវិភាជន៍បន្ថែមធនធានមូលនិធិឃុំ សង្កាត់ជូនកុមប្រឹក្សាឃុំ សង្កាត់សំរាប់ឆ្នាំ២០០៣ |
| 18 | 27/02/03 | ១៣៧ សហវ.ហម | ប្រកាស ស្តីពីការកែសំរួលគំរូបញ្ជីគណនេយ្យ មាតិកាថវិកា និងមាតិកាគណនីឃុំ សង្កាត់ |
| 19 | 28/03/03 | ១៧២ សហវ.ប្រក. | ប្រកាសណែនាំ ស្តីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់ |
| 20 | 25/07/03 | ០៥៧ អសជ.សណ | សេចក្តីណែនាំស្តីពីសវនកម្មគណនី និងប្រតិបត្តិការឃុំ សង្កាត់ |
| 21 | 30/09/03 | ៥៣៥៩ សហវ.ថហ. | ប្រកាស ស្តីពីការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០៤ជូនកុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស |
| 22 | 27/10/03 | ៨៨១ សហវ.ហម | ប្រកាស ស្តីពីការកែសំរួលគំរូតារាងរបាយការណ៍ មាតិកាថវិកា និងមាតិកាគណនីឃុំ សង្កាត់ |
| 23 | 24/11/03 | ៧០៤ សហវ.រតន | សេចក្តីណែនាំ ស្តីពីការបិទគណនីគំរោងឃុំ សង្កាត់ |
| 24 | 17/12/03 | ៧៤៤ សហវ.រតន | សេចក្តីណែនាំ ស្តីពីរបៀបបំពេញបែបបទលើទំរង់នានាទាក់ទងថវិកាឃុំ សង្កាត់ |
| 25 | 27/03/04 | ០៣៣ សហណ.គឃស | សេចក្តីណែនាំ ស្តីពីការបំពេញល័ក្ខខ័ណ្ឌ ដើម្បីទទួលបានការផ្ទេរ ធនធានមូលនិធិឃុំ សង្កាត់ |
| 26 | 05/07/04 | ២០២ សហវ.ប្រក | ប្រកាស ស្តីពីការកែសំរួល និងបំពេញបន្ថែមនូវគំរូតារាងរបាយការណ៍ មាតិកាថវិកា មាតិកាគណនីឃុំ សង្កាត់ |

## ឧបសម្ព័ន្ធ II: ការគាំទ្រផ្នែកក្របខ័ណ្ឌច្បាប់របស់កម្មវិធីសិលា និង PLG ដល់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

| លរ | កាលបរិច្ឆេទ | ក្របខ័ណ្ឌច្បាប់/ឯកសារ |
|---|---|---|
| **IV.** | **ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់** | |
| 1 | 14/02/02 | ប្រកាស ស្តីពីការជ្រើសរើសគ្រូបង្គោលសំរាប់ការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ |
| 2 | 29/04/02 | សេចក្តីណែនាំ ស្តីពីគោលការណ៍អប់រំ បណ្តុះបណ្តាល និងការកាសងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ |
| 3 | 29/04/02 | សេចក្តីណែនាំ ស្តីពីដំណើរការ និងយុទ្ធសាស្ត្រសំរាប់វគ្គបណ្តុះបណ្តាល ស្តីពីហិរញ្ញវត្ថុ និងការកសាងផែនការ |
| 4 | 03/02 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល តំរង់ទិសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីវិជ្ជការ រដ្ឋបាល និងការគ្រប់គ្រង |
| 5 | 05/02 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគណនេយ្យ និងហិរញ្ញវត្ថុឃុំ សង្កាត់ |
| 6 | 06/02 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
| 7 | 11/02 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំគំរោងឃុំ សង្កាត់ |
| 8 | 12/02 | ផែនការបណ្តុះបណ្តាលរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ឆ្នាំ២០០៣ |
| 9 | 01/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីលទ្ធកម្មគំរោងឃុំ សង្កាត់ និងការគ្រប់គ្រងកិច្ចសន្យា |
| 10 | 03/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ |
| 11 | 04/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីការសិក្សាផលប៉ះពាល់បរិស្ថាន និងលទ្ធកម្មជីធ្លី |
| 12 | 06/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីរដ្ឋបាលឃុំ សង្កាត់ និងការគ្រប់គ្រង |

| | | |
|---|---|---|
| 13 | 07/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ |
| 14 | 09/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីការចូលរួមរបស់ជនជាតិដើមភាគតិចក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
| 15 | 12/03 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីជំនាញសំរបសំរួល |
| 16 | 12/03 | ផែនការបណ្តុះបណ្តាលរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ឆ្នាំ២០០៤ |
| 17 | 02/04 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល និងសៀវភៅណែនាំសង្ខេប ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ សង្កាត់ |
| 18 | 8/03/04 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយែនឌ័រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ |
| 19 | 8/03/04 | សៀវភៅណែនាំ សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបន្ទុកការងារស្ត្រី និងកុមារ |
| 20 | 03/04 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល និងសៀវភៅណែនាំសង្ខេប ស្តីពីជំនាញតាមដាន និងវាយតំលៃគំរោងឃុំ សង្កាត់ |
| 21 | 08/04 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីការចុះបញ្ជីអាត្រានុកូលដ្ឋាន |
| 22 | 09/04 | ឯកសារណែនាំវគ្គបណ្តុះបណ្តាល ស្តីពីជំនាញហិរញ្ញវត្ថុឃុំ សង្កាត់ ( ថ្មី) |